ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៩៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ស៊ូ ផេង (XU FENG) ជនជាតិចិន សញ្ជាតិហ្វីលីពីន កើតនៅខេត្តហ្សិចាង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា ស៊ូ ដាហ្វា (XU DAFA) ១៧៨១

២០-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១០២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ណាវ៉ុន ហ៊ឹម (NAVON HAIM) ជនជាតអ៊ីស្រាអែល សញ្ជាតិអ៊ីស្រាអែល កើតនៅទីក្រុងហ្សេរុយសាឡិម ប្រទេសអ៊ីស្រាអែល ១៧៨២

២៥-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១៣៤ ស្តីពី ការតាំងស៊ប់មន្ត្រីរាជការ របស់ក្រសួង ស្ថាប័ន ទៅក្នុងឋានន្តរស័ក្តិ តាមលំដាប់ថ្នាក់ ចំនួន ៩៥ រូប ១៧៨៣

២៨-០២-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/១៦៣ ស្តីពី ការតែងតាំង ឯកឧត្តម ខៀវ ថារាមិត ជា ទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈ ស្មើ អគ្គនាយក ១៧៨៩

០១-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៦៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ នៃក្រសួងផែនការ ចំនួន ១២ រូប ១៧៩០

០១-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៦៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ចំនួន ៥៦ រូប ១៧៩១

០១-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៧០ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយឯក ដល់នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ១៧៩៣

០១-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៧១ ស្តីពី ការតែងតាំង ឯកឧត្តម ប្រាក់ ចំរើន ជា អនុរដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ១៧៩៤

០១-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៧២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០២ រូប ១៧៩៥

០១-៣-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៣១២/១៧៥ ស្តីពី ការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ១៧៩៦

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៧-៣-២០១២ -អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក ១៨០៨
០៥-៣-២០១២ -អនុក្រឹត្យលេខ ២៥៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨១៧
០៥-៣-២០១២ -អនុក្រឹត្យលេខ ២៥៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨១៩
០៥-៣-២០១២ -អនុក្រឹត្យលេខ ២៥៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨២០
០៥-៣-២០១២ -អនុក្រឹត្យលេខ ២៥៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៨២២
០៥-៣-២០១២ -អនុក្រឹត្យលេខ ២៥៩ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ចមន្ត្រីរាជការ ១៨២៤
០៥-៣-២០១២ -អនុក្រឹត្យលេខ ២៦០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៨២៥

III-ការិយាល័យក្រសួង

១-ទីស្តីការក្រសួងមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៨-០២-២០១២ -ប្រកាសលេខ ១៣៩ ឧរថ.មមជ.ប្រក ស្តីពី នីតិវិធី និង បែបបទ នៃការចុះបញ្ជីមាត្រាសាស្ត្រ និង ការផ្តល់អាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជា ១៨៦៤

២-ទីស្តីការក្រសួងមន្ត្រីក្រសួងពាណិជ្ជកម្ម

៣០-១២-២០១០ -លិខិតបញ្ជាក់លេខ ៥៨១៧ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែនិងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន ចំរើន និតា គ្រុប ១៨៦៩
៣០-១២-២០១០-លិខិតបញ្ជាក់លេខ ៥៨២៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន 952 បានយ៉ា គ្រុប គ្រេឌីង ១៨៧១
៣១-១២-២០១០-លិខិតបញ្ជាក់លេខ ៥៨៣៥ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែនិងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន អ៊ី-ឡាយត៍ (ខេមបូឌា) ១៨៧៣
៣១-១២-២០១០-លិខិតបញ្ជាក់លេខ ៥៨៣៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ផាតស្មូន (ខេមបូឌា) ខូ អិលធីឌី ១៨៧៥
៣១-១២-២០១០-លិខិតបញ្ជាក់លេខ ៥៨៤០ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការប្តូរទ្រង់ទ្រាយរចនាសម្ព័ន្ធ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន តាំម៉ិនតែល ១៨៧៧

១០-០១-២០១១ -លិខិតបញ្ជាក់លេខ ០០៧៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ័រេស អេស៊ា ខបភើរេសិន** ១៨៧៩

១០-០១-២០១១ -លិខិតបញ្ជាក់លេខ ០០៨០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូ ឆាយណា ខមមើស
អ៊ិនធើណេសិនណល ប៊ីហ្សនេស** ១៨៨១

១០-០១-២០១១ -លិខិតបញ្ជាក់លេខ ០០៨៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តាព្រហ្ម ត្រេឌីង** ១៨៨៣

១០-០១-២០១១ -លិខិតបញ្ជាក់លេខ ០០៩០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឥន្ទធនូ (ខេមបូឌា)
ត្រេឌីង** ១៨៨៥

១០-០១-២០១១ -លិខិតបញ្ជាក់លេខ ០០៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពន្លឺ និម្មិត អ៊ែតវ៉ានស៍
ត្រេឌីង** ១៨៨៧

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ហោរភាស គម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ូ ហ្វេង** (XU FENG) ជនជាតិចិន សញ្ជាតិហ្វីលីពីន កើតថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៨ នៅខេត្តហ្សឺចាង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ស៊ូ ដាហ្វា** (XU DAFA)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រសា.១២០២.១០០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ: ១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
ស៊ុំ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១២/១០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ណាវ៉ុន ហៃម** (NAVON HAIM) ជនជាតិអ៊ីស្រាអែល សញ្ញាតិអ៊ីស្រាអែល កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៥៨ នៅទីក្រុងហ្សេរុយសាឡិម ប្រទេសអ៊ីស្រាអែល ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible] ១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
សយ សុខា

[illegible].១២០២.១០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០២១២/១៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការ របស់ក្រសួង ស្ថាប័ន ទៅក្នុងឋានន្តរសក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដូចមានរាយនាមខាងក្រោមៈ

ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរសក្តិ និងថ្នាក់
ទីស្តីការគណៈរដ្ឋមន្ត្រី			
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១១ តទៅ			
១	**ស៊ិន សេរីវឌ្ឍនា**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
២	**គង់ អភិវឌ្ឍន៍**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
៣	**ជា ពិសិដ្ឋនរៈ**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
៤	**អ៊ឹម រដ្ឋារ៉ា**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
៥	**ខ៊ាន់ សម្ផស្ស**	ស	អនុមន្ត្រី ថ្នាក់លេខ ១១
៦	**ឈិត រតនៈ**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
៧	**កុច ការោកាខែន**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
៨	**ស្រ៊ាង ផានិត**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
៩	**យ៉ម ផារ៉ូត**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
១០	**ជុំ សុភមករា**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍			
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១១ តទៅ			
១	**ឃឹង ខ៊ាន់នី**	ប	អនុមន្ត្រី ថ្នាក់លេខ ១១
ក្រសួងអភិវឌ្ឍន៍ជនបទ			
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១១ តទៅ			
១	**ឡេង គីឈ័ង**	ប	អនុមន្ត្រី ថ្នាក់លេខ ១១

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ក្រសួងកិច្ចការនារី			
តាំងស៊ប់គិតចាប់ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១ តទៅ			
១	ហេង វិសាល	ប	អនុមន្ត្រី ថ្នាក់លេខ ១១
ក្រសួងយុត្តិធម៌			
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ តទៅ			
១	ខៀវ និត្យវណ្ណៈ	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
២	ឌិន មុនី	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៣	ជាករុណា	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
៤	តាំង សុផា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៥	ផ្លូង ប្រុស	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៦	ផុន ចាន់សុធា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៧	ម៉ែន គីរុណា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៨	លី សុវណ្ណា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៩	សំបូរ សម្ផស្ស	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
១០	សំអឿន ធីតា	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
១១	សៃ ម៉េង	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១២	សំរិទ្ធិ សិរីកុសុមា	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
១៣	ហ៊ុន សុភាព	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
១៤	ឯក សារ៉ាត់	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១៥	កែវ ប្រាថ្នា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១៦	ខែក ខេមរៈ	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១៧	ខាត់ ច័ន្ទណា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១៨	ធឹង វ៉ាន់ឆៃ	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១៩	ធឹង វ៉ាន់ថង	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
២០	ជួន ជា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
២១	ម៉ែន ចំណាន	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
២២	ឡាយ វិសាល	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
២៣	អេង រស្មី	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
២៤	ឃុត ស៊ាងអៃ	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
២៥	ជា សុខតារា	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
២៦	រឿន លីណា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
២៧	សុខ សុវណ្ណា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

២៨	សូ សុខហុង	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
ក្រសួងធម្មការ និងសាសនា			
តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១០ តទៅ			
១	កន ប៊ុនថាន	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
២	ញ៉ែម និមល	ស	អនុមន្ត្រី ថ្នាក់លេខ ១៤
៣	មោក ឆ្លូនលីណា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៤	អ៊ុត ប៊ុនឈឿន	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៥	ស៊ាន សេរីភក្តី	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៦	សរ លីនដា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៧	ទិន រិទ្ធី	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៨	នាក់ យិតថូ	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
៩	ចៅ លន់តូរ៉ា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១០	ផាន់ សំបឿន	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១១	ឆ្លូន កក្កដា	ប	អនុមន្ត្រី ថ្នាក់លេខ ១៤
១២	មៀច អ៊ាង	ប	អនុមន្ត្រី ថ្នាក់លេខ ១៤

មាត្រា ២ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការ របស់ក្រសួងធម្មការ និងសាសនា ទៅក្នុងឋានន្តរសក្តិគ្រូបង្រៀនកម្រិតឧត្តម នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម គិតចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០ តទៅ ដូចមានរាយនាមខាងក្រោមៈ

ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរសក្តិ និងថ្នាក់
១	ព្រហ្ម សារ៉ែន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤
២	សាន ស៊ុយ	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤
៣	រឿង ពិសី	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤
៤	ខុន សុខនី	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤
៥	រាម រិន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤
៦	សៅ ស្ងួនសីលា	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤
៧	ហ៊ុំ សុភៀន	ប	គ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ ១៤

មាត្រា ៣ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការ របស់ក្រសួងសុខាភិបាល ទៅក្នុងឋានន្តរសក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ គិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ តទៅ ដូចមានរាយនាមខាងក្រោមៈ

ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរសក្តិ និងថ្នាក់
១	ងា ហេងឡុង	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

២	យន ចរិយា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
៣	វង្ស អេង	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
៤	តន់ ឆៃលីម	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
៥	ខាំ សោភា	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
៦	ប៊ី ដាវី	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
៧	យក់ ពុធវិសាល	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
៨	អ៊ឹម បុត្រ	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
៩	ហេង ស៊ីវម៉ី	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
១០	វ៉ា និមល	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
១១	ឈួយ គឹមឈឿន	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
១២	ភាន់ កុសលធីរ៉ា	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
១៣	គៀត សោភា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
១៤	សំ វណ្ណា	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
១៥	ញឹម សុវណ្ណវត្តី	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
១៦	ភង សោភ័ណ្ឌា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
១៧	ភង ពុទ្ធា	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
១៨	ឈួន សុធី	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
១៩	ខាត់ សុផល	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
២០	ថេង ភក្តី	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
២១	ភង សុធារ៉ា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
២២	ឈិន ចាន់ធុន	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
២៣	ស៊ូ ធីរ៉ារ័ត្ន	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
២៤	ទា ស៊ុយផេង	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
២៥	ឃុត សុផល	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
២៦	ផាន់ ចរិយា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
២៧	មួង បញ្ញា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
២៨	ឡាយ គង់	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
២៩	សាយ សារិន្ទរ៉ូហ្សិត	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
៣០	ហ៊ិន លក្ខិណា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
៣១	គៀត តារម្យ	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤
៣២	កែប បញ្ញា	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣
៣៣	សុខ កុសលពិសិដ្ឋ	ប	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៣

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣៤	ទ៉ា ពុធនាថ	ស	មន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១៤

មាត្រា ៤ : ត្រូវបានតាំងស៊ប់មន្ត្រីរាជការ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅក្នុងឋានន្តរសក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ គិតចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១១ តទៅ ដូចមាននាមខាងក្រោម:

ល.រ	នាម និងគោត្តនាម	ភេទ	ឋានន្តរសក្តិ និងថ្នាក់
១	សៅ តារារ័ត្ន	ប	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤

មាត្រា ៥ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៦ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៧ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ១៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊យ សុខា

នស.រកត.០២១២.១៣៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០២១២/១៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តយ៉ា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម **ខៀវ ថារាទិត្យ** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.១២០២.១៦៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២

លេខ ១៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ នៃក្រសួងផែនការ ចំនួន ១២រូប ដែលមានស្នាដៃល្អក្នុងការ
ចូលរួមគម្រោងជំរឿនសហគ្រាសឆ្នាំ២០១១ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស ជាតូបការ

- ឯកឧត្តម អ៊ិន សារឿង

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

១- ឯកឧត្តម សន ស៊ីថន
២- ឯកឧត្តម ទី ហៀង
៣- ឯកឧត្តម សេង សឿន

គ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

១- លោក Yasujiro Suzuki
២- លោក Fumihiko Nishi
៣- លោក Shigeru Kawasaki
៤- លោក Paul Cheung

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១- លោក ហោ ដារិទ្ធ
២- លោក លឹម ពេញ

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១- លោក ឃិន សុខលក្ខណ៍
២- លោក សាំង ឡុងឌី

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣៩៩.១២០៣.១៧៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២

លេខ ១៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១២
អគ្គ[illegible]ទីរាជរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/២៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ចំនួន ៥៦ រូប មានគុណបំណាច់ចំពោះជាតិមាតុភូមិ ព្រមជាមួយនេះ ឯកឧត្តម អស់លោក លោកស្រីបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការបំពេញភារកិច្ចទទួលបានស្នាដៃល្អប្រសើរ លើការងាររដ្ឋបាល ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម	ទេព	ធន	៣-លោក	សៃ	សាមុត
២-ឯកឧត្តម	ហ៊ុយ	ណារ៉ា	៤-លោក	ឈឹម	កន

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឯកឧត្តម	កៀង	សុភ័ណ	១០-លោក	ប្រាក់	អង្គារ៉ា
២-ឯកឧត្តម	ម៉ម	សុផាណា	១១-លោក	អ៊ិត	សុត្ថា
៣-ឯកឧត្តម	លឹម	ហោ	១២-លោក	ឡោ	ដារុជ
៤-ឯកឧត្តម	សៀក	វណ្ណា	១៣-លោក	សេង	ថានី
៥-ឯកឧត្តម	សរ	សុវណ្ណ	១៤-លោក	សរ	សាមេធា
៦-ឯកឧត្តម	ឌុច	វនទីតូ	១៥-លោក	ជី	ស៊ីថា
៧-លោក	ហាង្ស	ប៊ុណ្ណាក់	១៦-លោក	សួន	សុផា
៨-លោកស្រី	សួស	សុផល	១៧-លោក	មាស	ប៊ុនធឿន
៩-លោក	សារេត	បូរាមី	១៨-លោក	ម៉ាន់	សុផាត

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-លោក មាន ច័ន្ទរ៉ាន់នី
២-លោក បេងហុង សុជាតិខេមរ៍
៣-លោកស្រី ម៉ៅ ឧស្សាហ៍
៤-លោក ប៉ែន សុផល
៥-លោក ម៉ិញ សំអឿន
៦-លោក ម៉េង ប៊ុណ្ណារិទ្ធ
៧-លោក វង្ស សាក់ត
៨-លោក ម៉ៃ សុជាត
៩-លោក រ័ត្ន ពិសិដ្ឋ
១០-លោក អ៊ុំ បូរិទ្ធ
១១-លោក ប៉ុល ចាវ័ន្ត
១២-លោក សេក សុធីរិទ្ធ
១៣-លោក អេ ប៊ុនធឿន
១៤-លោក កែវ សៀងសោភ័ណ
១៥-លោក សុក សិត
១៦-លោក ទឹម ស៊ីណាត
១៧-លោក នៃ សុផល

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-ឯកឧត្តម ឈឹម កៃលាង
២-ឯកឧត្តម សាយ នីដ្ឋា
៣-ឯកឧត្តម សុខ សូនី
៤-លោក ប៉ែន ច័ន្ទសុខខេមរា
៥-លោក សោ វណ្ណា
៦-លោក ញ៉ឹប ផន
៧-លោក ម៉ៅ ច័ន្ទរស្មី
៨-លោកស្រី គឹម ធីយ៉ា
៩-លោក សុខ ស៊ីចាន់
១០-លោក សុខ កុសល
១១-លោក ហៅ សូផាន់ណារ៉ា
១២-លោក គាប់ ម៉ាឡៃ
១៣-លោក យស់ ឆោមណារ៉ាឌី
១៤-លោក នួន ប៉ុក
១៥-លោក ប៊ី ជីវ័នតារា

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-លោក សុខ សេងយ៉ន
២-លោក វឌ្ឍី វណ្ណារ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារល-១២០៣-១៧៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១២

លេខៈ ១៥១ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១២
អគ្គលេខ[illegible]ទីរាជរដ្ឋាភិបាល

[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៧៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ឯក ដល់នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ទោ **អ៊ុំ ម៉ារ៉ា** អត្តលេខ ០០១១២៨

២-ឧត្តមសេនីយ៍ទោ **ស ថាវី** អត្តលេខ ០០១៥០០

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

ចរល. ១២០៣. ១៧៥

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២

លេខៈ ១៧៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១២

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ឃន សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៧៦១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឆ្នាក់ ចំរើន** ជាអនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

តារាង-១២០៣-១៧៦៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១២

លេខៈ ១៧២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១២
[illegible] រដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៩៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា
ក្នុងវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តបន្ទាយមានជ័យ

នូវ

ក. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម តឹង ង៉ាន់ថូ

ខ. គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

១- ឯកឧត្តម ម៉ា ស៊ុនហួត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible]

លេខ:១៧៩ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សយ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៣១២/១៧៥

ស្ដីពី
ការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២

ត្រាស់បង្គាប់
ជំពូកទី១
បទប្បញ្ញត្តិទូទៅ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

មាត្រា ១.-

ត្រូវបានបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ដែលសរសេរជាអក្សរកាត់ថា **ប.ក.ទ.ក.** ជានីតិបុគ្គលនៃនីតិសាធារណៈ ដែលបានទទួលសិទ្ធិពីរាជរដ្ឋាភិបាល មានស្វ័យភាពក្នុងការងារត្រួតពិនិត្យ និងគ្រប់គ្រងខាងផ្លូវបច្ចេកទេសនិងរដ្ឋបាល លើការស្ថាបនា ការធ្វើប្រតិបត្តិការ ការផ្តល់ និងការប្រើប្រាស់បណ្តាញនិងសេវាទូរគមនាគមន៍ព្រមទាំងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានដូចមានចែងនៅក្នុងមាត្រា៣នៃព្រះរាជក្រឹត្យនេះ។

មាត្រា ២.-

វាក្យសព្ទដែលប្រើក្នុងព្រះរាជក្រឹត្យនេះ មានន័យដូចខាងក្រោម៖

- **បញ្ញត្តិករទូរគមនាគមន៍កម្ពុជា (ប.ក.ទ.ក.)** សំដៅដល់អ្នករៀបចំបទប្បញ្ញត្តិនានានៃវិស័យទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា
- **កាតព្វកិច្ចសេវាសកល** សំដៅដល់កាតព្វកិច្ចបង្កើតសេវាដែលប្រជាពលរដ្ឋគ្រប់គ្នាមានលទ្ធភាពប្រើប្រាស់បាន
- **តារាងបែងចែកប្រេកង់** សំដៅដល់តារាងបែងចែករលកអាកាសវិទ្យុទាំងអស់ដែលបង្ហាញនូវការបែងចែកនិងការប្រើប្រាស់បង់នីមួយៗនៃប្រេកង់
- **ទីតាំងស្ថានីយទូរគមនាគមន៍** សំដៅដល់បរិក្ខារវិទ្យុនិងទូរស័ព្ទ ជាគ្រឿងឬប្រព័ន្ធដែលប្រើប្រាស់សម្រាប់ឆ្លើយឆ្លងព័ត៌មានឯកជនឬសាធារណៈ និងមានទីតាំងចល័តឬនៅនឹងមួយកន្លែង
- **ទូរគមនាគមន៍** សំដៅដល់ការផ្សាយ ការបញ្ជូន ឬការទទួលស៊ីញ៉ាល់ អក្សរ រូបភាព សំឡេង ឬព័ត៌មានគ្រប់ប្រភេទតាមមធ្យោបាយខ្សែកាប តាមអុបទិក តាមវិទ្យុអគ្គីសនី ឬតាមប្រព័ន្ធអេឡិចត្រូម៉ាញ៉េទិកផ្សេងៗទៀត
- **បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** សំដៅដល់សំណុំនៃទំនិញ សេវា សម្ភារៈដែលបានប្រើប្រាស់សម្រាប់ផលិត ទុកធ្វើប្រព្រឹត្តកម្ម ចែកចាយ និងផ្លាស់ប្តូរព័ត៌មាន
- **ប្លង់លេខទូរស័ព្ទនិងអាសយដ្ឋានអេឡិចត្រូនិក** សំដៅដល់ប្លង់ដែលពាក់ព័ន្ធនឹងការកំណត់លេខរៀងនិងអាសយដ្ឋានអេឡិចត្រូនិក
- **សេវាទូរគមនាគមន៍** សំដៅដល់សេវានៃប្រភេទទូរគមនាគមន៍ក្នុងនោះរួមមាន ទូរស័ព្ទ ទូរពុម្ព ទូរលេខ ទូរសារ អ៊ីនធឺណេត អ៊ីម៉ែល ទិន្នន័យ សេវាភ្ជាប់ដោយប្រព័ន្ធកុំព្យូទ័រ និងសេវាផ្សេងៗទៀត

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- បណ្តាញទូរគមនាគមន៍ សំដៅដល់ប្រព័ន្ធដែលប្រើឬមានសមត្ថភាពក្នុងការប្រើប្រាស់ សម្រាប់ផ្តត់ផ្គង់សេវាកម្មទូរគមនាគមន៍
- ផែនការប្រេកង់ស៍ជាតិ សំដៅដល់ផែនការដែលពាក់ព័ន្ធនឹងប្រេកង់ស៍ សម្រាប់ប្រើប្រាស់នៅប្រទេសកម្ពុជា
- ពិន័យអន្តរការណ៍ ប្រាក់ពិន័យដែល **ន.ក.ទ.ក.** មានសមត្ថកិច្ចតម្រូវឲ្យជនល្មើសបង់ស្របតាមទោសប្បញ្ញត្តិនៃច្បាប់ទូរគមនាគមន៍
- សម្ភារបរិក្ខារ សំដៅដល់ផ្នែកណាមួយនៃហេដ្ឋារចនាសម្ព័ន្ធរបស់បណ្តាញទូរគមនាគមន៍ រួមមាន ខ្សែកាប បន្ទប់បែងចែកបណ្តាញ សសរទូរស័ព្ទ បង្គោលអង់តែន រូងផ្លូវក្រោមដី បំពង់ទុយយោ អន្លង់ រណ្តៅ ជន្ទល់ ឬបរិក្ខារផ្សេងៗទៀត
- អាសយដ្ឋានអេឡិចត្រូនិក សំដៅដល់លេខឬអក្សរអេឡិចត្រូនិក សម្រាប់សម្គាល់អាសយដ្ឋានអ៊ីម៉ែល កុំព្យូទ័រ ឬឧបករណ៍ប្រហាក់ប្រហែល
- អាជ្ញាបណ្ណ សំដៅដល់អាជ្ញាបណ្ណបណ្តាញស្តង់ដា អាជ្ញាបណ្ណបណ្តាញ ដោយឡែក អាជ្ញាបណ្ណសេវាកម្មស្តង់ដា និងអាជ្ញាបណ្ណសេវាកម្មដោយឡែក
- អាជ្ញាបណ្ណប្រេកង់ស៍ សំដៅដល់អាជ្ញាបណ្ណផ្តល់ឲ្យបុគ្គលឬអង្គភាព ក្នុងការប្រើប្រាស់ប្រេកង់ស៍
- អាជ្ញាបណ្ណដោយឡែក សំដៅដល់អាជ្ញាបណ្ណចេញឲ្យអង្គភាពជាក់លាក់មួយ ដែលមានលក្ខខណ្ឌតម្រូវឲ្យអង្គភាពនោះបំពេញ
- អាជ្ញាបណ្ណបណ្តាញដោយឡែក សំដៅដល់អាជ្ញាបណ្ណ សម្រាប់ការសាងសង់ ម្ចាស់កម្មសិទ្ធិ និងការប្រតិបត្តិបណ្តាញទូរគមនាគមន៍ច្បាស់លាស់មួយ ចេញឲ្យអង្គភាពជាក់លាក់មួយ ដែលមានលក្ខខណ្ឌតម្រូវឲ្យអង្គភាពនោះបំពេញ
- អាជ្ញាបណ្ណសេវាកម្មដោយឡែក សំដៅដល់អាជ្ញាបណ្ណ សម្រាប់ផ្គត់ផ្គង់សេវាទូរគមនាគមន៍ច្បាស់លាស់មួយ ចេញឲ្យអង្គភាពជាក់លាក់មួយ ដែលមានលក្ខខណ្ឌតម្រូវឲ្យអង្គភាពនោះបំពេញ
- អ្នកទទួលអាជ្ញាបណ្ណ សំដៅដល់អ្នកកាន់អាជ្ញាបណ្ណក្នុងក្របខ័ណ្ឌព្រះរាជក្រឹត្យនេះ
- អ្នកទទួលអាជ្ញាបណ្ណបណ្តាញ សំដៅដល់អ្នកកាន់អាជ្ញាបណ្ណបណ្តាញស្តង់ដា ឬបណ្តាញដោយឡែក តាមបរិបទតម្រូវ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

- អ្នកទទួលអាជ្ញាបណ្ណសេវាកម្ម សំដៅដល់អ្នកកាន់អាជ្ញាបណ្ណសេវាកម្មស្តង់ដា ឬ ដោយឡែក តាមបរិបទតម្រូវ
- អាជ្ញាបណ្ណស្តង់ដា សំដៅដល់អាជ្ញាបណ្ណដែលផ្តល់ឲ្យដោយមានខ្លឹមសារនិងលក្ខខណ្ឌ ដូចគ្នាចំពោះអង្គភាពច្រើនសម្រាប់ប្រភេទដូចគ្នា
- អាជ្ញាបណ្ណសេវាកម្មស្តង់ដា សំដៅដល់អាជ្ញាបណ្ណសម្រាប់ការផ្គត់ផ្គង់សេវា ទូរគមនាគមន៍ច្បាស់លាស់មួយ ដោយមានខ្លឹមសារនិងលក្ខខណ្ឌដូចគ្នា ចំពោះ អង្គភាពច្រើន ដែលត្រូវបានទទួលអាជ្ញាបណ្ណ សម្រាប់ប្រភេទដូចគ្នានៃសេវាកម្ម
- អាជ្ញាបណ្ណបណ្តាញស្តង់ដា សំដៅដល់អាជ្ញាបណ្ណសម្រាប់ការសាងសង់ ម្ចាស់កម្មសិទ្ធិ និងការប្រតិបត្តិបណ្តាញទូរគមនាគមន៍ច្បាស់លាស់មួយ ដោយមានខ្លឹមសារនិង លក្ខខណ្ឌដូចគ្នា សម្រាប់ប្រភេទដូចគ្នានៃបណ្តាញ។

ជំពូកទី២
មុខងារនិងភារកិច្ចរបស់ ប.ក.ន.ក.

មាត្រា ៣.-

ប.ក.ន.ក. មានមុខងារនិងភារកិច្ចដូចតទៅ៖

ក- អនុវត្តគោលនយោបាយវិស័យទូរគមនាគមន៍ ដែលត្រូវបានកំណត់ឡើងដោយរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ខ- ជំរុញឲ្យមានរចនាសម្ព័ន្ធវិស័យទូរគមនាគមន៍សមស្របតាមគោលនយោបាយវិស័យ ទូរគមនាគមន៍។

គ- ជំរុញនិងទ្រទ្រង់បរិស្ថានទីផ្សារទូរគមនាគមន៍ ដើម្បីឲ្យមានការប្រកួតប្រជែងប្រកបដោយ យុត្តិធម៌និងប្រសិទ្ធភាពក្នុងវិស័យទូរគមនាគមន៍។

ឃ-ការពារផលប្រយោជន៍សាធារណជនក្នុងការទទួលសេវាកម្ម ដែលផ្តល់ដោយអ្នកទទួល អាជ្ញាបណ្ណ។

ង- រៀបចំនិងដាក់ឲ្យអនុវត្តបទប្បញ្ញត្តិសម្រាប់វិស័យទូរគមនាគមន៍រួមមាន៖

- ចេញបទប្បញ្ញត្តិដើម្បីតម្រូវឲ្យអ្នកទទួលអាជ្ញាបណ្ណ ធ្វើការតភ្ជាប់បណ្តាញ និងអនុញ្ញាតឲ្យប្រតិបត្តិករដទៃប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម
- តាមដាននិងគ្រប់គ្រងថ្លៃសេវាទូរគមនាគមន៍

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

- ចាត់តាំងនិងគ្រប់គ្រងកម្មវិធីកាតព្វកិច្ចនៃការប្រើប្រាស់សេវាសកល
- រៀបចំឲ្យមានស្តង់ដាសម្រាប់ប្រើប្រាស់ក្នុងវិស័យទូរគមនាគមន៍
- រៀបចំនិងគ្រប់គ្រងប្លង់លេខទូរស័ព្ទនិងអាសយដ្ឋានអេឡិចត្រូនិក
- រៀបចំនិងគ្រប់គ្រងប្រព័ន្ធនិងសេវាអ៊ីនធឺណេត
- រៀបចំនិងគ្រប់គ្រងប្លង់ជាតិប្រេកង់វិទ្យុ រួមទាំងការបែងចែកនិងចេញអាជ្ញាបណ្ណប្រេកង់ ដោយមានកិច្ចសហការជាមួយក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។
- កំណត់ខ្លឹមសារនិងលក្ខខណ្ឌនៃអាជ្ញាបណ្ណទូរគមនាគមន៍
- ចេញ កែសម្រួល ព្យួរ ផ្ទេរ និងដកហូតអាជ្ញាបណ្ណ
- តម្រូវឲ្យអ្នកទទួលអាជ្ញាបណ្ណទាំងអស់និងបុគ្គលដទៃទៀតគោរពតាមវិធាន និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ
- ធ្វើជាអ្នកសម្របសម្រួលវិវាទទាំងឡាយរវាងអ្នកទទួលអាជ្ញាបណ្ណនិងអ្នកទទួលអាជ្ញាបណ្ណ និងរវាងអ្នកទទួលអាជ្ញាបណ្ណនិងអ្នកប្រើប្រាស់សេវាទូរគមនាគមន៍។

ច- កំណត់បណ្តាញនិងសេវាទូរគមនាគមន៍ ដែលត្រូវមានអាជ្ញាបណ្ណស្តង់ដាឬអាជ្ញាបណ្ណដោយឡែកនិងកំណត់មូលដ្ឋានលក្ខណសម្បត្តិសម្រាប់ចេញអាជ្ញាបណ្ណនេះ។

ឆ- ផ្តល់សេចក្តីណែនាំនិងជួយសម្រួលដល់អ្នកប្រកបរបរខាងវិស័យទូរគមនាគមន៍។

ជ- រៀបចំរបាយការណ៍និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អំពីបញ្ហាពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍។

ឈ- ផ្តល់របាយការណ៍ប្រតិបត្តិការនិងហិរញ្ញវត្ថុពាក់ព័ន្ធនឹងសកម្មភាពរបស់ប្រតិបត្តិករទូរគមនាគមន៍ជារៀងរាល់ឆ្នាំ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ញ- លើកសំណើសុំកំណត់តម្លៃអាជ្ញាបណ្ណសម្រាប់អ្នកទទួលអាជ្ញាបណ្ណគ្រប់ប្រភេទ។

ដ- ចេញបទប្បញ្ញត្តិនិងបទបញ្ជាសមស្រប ព្រមទាំងបញ្ជាផ្អាកជាបណ្តោះអាសន្នឬជាស្ថាពរ ចំពោះប្រតិបត្តិការបណ្តាញនិងការផ្តល់សេវាទូរគមនាគមន៍។

ពិន័យអន្តរការណ៍ ផ្អាកការផ្តល់ និងប្រើប្រាស់សេវាកម្មទូរគមនាគមន៍ ព្យួរឬដកហូតអាជ្ញាបណ្ណ ចំពោះការរំលោភលើច្បាប់និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់បញ្ញត្តិករ

ទូរគមនាគមន៍កម្ពុជា។

ឌ- ផ្សព្វផ្សាយបទប្បញ្ញត្តិ សេចក្តីណែនាំ លិខិតបទដ្ឋាន និងឯកសារដទៃទៀត ដែលខ្លួនបានរៀបចំឡើង។

ឍ-បណ្តុះបណ្តាលនិងអភិវឌ្ឍបុគ្គលិករបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

ណ- ត្រួតពិនិត្យទីតាំងស្ថានីយទូរគមនាគមន៍។

ត- ជំរុញឲ្យមានការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យាទូរគមនាគមន៍ បច្ចេកវិទ្យាព័ត៌មាន ឧស្សាហកម្មទូរគមនាគមន៍។

ថ- ចេញបទប្បញ្ញត្តិស្តីពីការរៀបចំរចនាសម្ព័ន្ធ ការគ្រប់គ្រងបុគ្គលិក ថវិកាហិរញ្ញវត្ថុ កម្មសិទ្ធិនិងមុខងារដទៃទៀតនៃទីស្នាក់ការបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

ទ- ផ្តល់ការយល់ព្រមលើថវិកាសម្រាប់ទីស្នាក់ការបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

ធ- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាលនិងបទប្បញ្ញត្តិច្បាប់ជាធរមាន។

ជំពូកទី៣
សមាជិកភាព ប.ក.ទ.ក.

មាត្រា ៤.—

ប.ក.ទ.ក.មានសមាសភាពចំនួន៣(បី)រូប ដែលក្នុងនោះមានប្រធាន១(មួយ)រូបនិងសមាជិក ២(ពីរ)រូប។

ប្រធាននិងសមាជិកត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទៅនាយករដ្ឋមន្ត្រី មានអាណត្តិ៣(បី)ឆ្នាំ ហើយត្រូវបញ្ចប់ក្នុងពេលខុសគ្នា លើកលែងតែក្នុងអាណត្តិដំបូងដូចមានចែងក្នុងមាត្រា២៣នៃព្រះរាជក្រឹត្យនេះ។

ប្រធានមានឋានៈស្មើរដ្ឋលេខាធិការ និងសមាជិកមានឋានៈស្មើអនុរដ្ឋលេខាធិការ។

ប្រធាននិងសមាជិក **ប.ក.ទ.ក.** អាចត្រូវបានតែងតាំងអាណត្តិបន្តទៀតបាន។

មាត្រា ៥.—

បុគ្គលដែលអាចត្រូវបានជ្រើសរើសជាប្រធាននិងសមាជិក **ប.ក.ទ.ក.**បានត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

- មានសញ្ញាបត្រចាប់ពីកម្រិតឧត្តមសិក្សាឡើងទៅក្នុងផ្នែកវិស្វកម្មទូរគមនាគមន៍ ឬនីតិសាស្ត្រឬសេដ្ឋកិច្ចឬគណនេយ្យឬហិរញ្ញវត្ថុ
- មានបទពិសោធការងារយ៉ាងតិច៥(ប្រាំ)ឆ្នាំពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- មានសមត្ថភាពការងារ មានភាពស្អាតស្អំ និងមានគុណធម៌
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋណាមួយឬធ្លាប់ទទួលការផ្តន្ទាទោសដូចចែងខាងលើ តែត្រូវបានទទួលនីតិសម្បទារួចហើយ។

មាត្រា ៦.-

ក្នុងអាណត្តិរបស់ខ្លួន ប្រធាននិងសមាជិក **ន.ក.ទ.ក.** មានវិសមិតភាពជាមួយមុខងារជាមន្ត្រីរាជការ ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឬជាទីប្រឹក្សាជំនួយការនៃក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

សាមីជនដែលកំពុងបម្រើការងារដូចមានចែងក្នុងកថាខណ្ឌខាងលើ ហើយត្រូវបានទទួលការតែងតាំងជាប្រធានឬជាសមាជិក **ន.ក.ទ.ក.** ត្រូវធ្វើលិខិតសុំលាលែងចេញពីមុខតំណែងឬព្យួរការងារជាបណ្តោះអាសន្នសម្រាប់រយៈពេលបំពេញការងារក្នុងអាណត្តិរបស់ខ្លួន។

មាត្រា ៧.-

ប្រធាននិងសមាជិក **ន.ក.ទ.ក.** ត្រូវធ្វើការពេញម៉ោងនៅ **ន.ក.ទ.ក.** និងមិនត្រូវធ្វើការឬយល់ព្រមទទួលកម្រៃពីសកម្មភាពផ្សេងៗក្នុងវិស័យពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនឡើយ។

មាត្រា ៨.-

ប្រធាននិងសមាជិកព្រមទាំងមន្ត្រីទាំងអស់របស់ **ន.ក.ទ.ក.** មិនអាចមានភាគហ៊ុនដោយផ្ទាល់ឬមានផលប្រយោជន៍សេដ្ឋកិច្ចឬមានមុខនាទីជាមួយអ្នកទទួលអាជ្ញាបណ្ណឬអ្នកសុំអាជ្ញាបណ្ណបានឡើយ ប៉ុន្តែអាចធ្វើជាអ្នកជាវឬអ្នកប្រើប្រាស់សេវារបស់អ្នកទទួលអាជ្ញាបណ្ណ។

ក្នុងអាណត្តិរបស់ខ្លួន ប្រធាននិងសមាជិកទាំងអស់របស់ **ន.ក.ទ.ក.** ព្រមទាំងសហព័ទ្ធឬកូនមិនអាចចូលបម្រើការងារឬទទួលតំណែងណាមួយជាទីប្រឹក្សាឬជាអ្នកពិគ្រោះការងារ និងមិនអាចមានភាគហ៊ុនឬបណ្ណវតនាគារឬមានផលប្រយោជន៍ជាប្រាក់ជាមួយអ្នកកាន់អាជ្ញាបណ្ណឬជាមួយបុគ្គលដទៃទៀតដែលមានទំនាក់ទំនងក្នុងការផ្តល់សេវាកម្មទូរគមនាគមន៍ឬដំណើរការដែលពាក់ព័ន្ធណាមួយបានឡើយ។

មាត្រា ៩.-

តំណែងប្រធានឬសមាជិក **ន.ក.ទ.ក.** ត្រូវចាត់ទុកថានៅទំនេរ នៅពេលដែលសាមីជនៈ

- ទទួលមរណភាព
- លាលែងពីមុខតំណែង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- បាត់បង់សមត្ថភាពការងារខាងបញ្ញាស្មារតីនិងកាយសម្បទា
- មានកំហុសធ្ងន់ធ្ងរនិងខ្វះការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចរបស់ខ្លួន
- ត្រូវបានផ្តន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋ។

មាត្រា ១០.-

ក្នុងករណីដែលតំណែងប្រធានឬសមាជិក **ម.ភ.ឆ.ភ.** នៅទំនេរមុនចប់អាណត្តិ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរៀបចំសមាសភាពថ្មីស្នើទៅនាយករដ្ឋមន្ត្រី ដើម្បីស្នើសុំតែងតាំងបំពេញអាណត្តិរបស់ប្រធានឬសមាជិកដែលនៅទំនេរនោះ។

មាត្រា ១១.-

ក្នុងរយៈពេល២(ពីរ)ឆ្នាំចាប់ពីពេលបញ្ចប់អាណត្តិឬលាលែងពីមុខតំណែងរបស់ខ្លួន ប្រធាននិងសមាជិក **ម.ភ.ឆ.ភ.** មិនត្រូវបានអនុញ្ញាតឲ្យចូលបម្រើការងារ ឬមានទំនាក់ទំនងជាទីប្រឹក្សា ឬជាអ្នកជំនាញការ ឬជាអ្នកពិគ្រោះយោបល់ជូនអ្នកទទួលអាជ្ញាបណ្ណទូរគមនាគមន៍ណាមួយបានឡើយ។

មាត្រា ១២.-

ប្រាក់បៀវត្សរ៍ ប្រាក់បំណាច់ និងអត្ថប្រយោជន៍ផ្សេងៗទៀត របស់ប្រធាននិងសមាជិក **ម.ភ.ឆ.ភ.** ត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជំពូកទី៤
ការប្រព្រឹត្តទៅនៃ ម.ភ.ឆ.ភ.

មាត្រា ១៣.-

ប្រធាននិងសមាជិក **ម.ភ.ឆ.ភ.** អាចរួមប្រជុំគ្នាបានតាមតម្រូវការចាំបាច់ ដោយមានការស្នើពីប្រធានឬសមាជិកទាំង២(ពីរ)រូប។

ការប្រជុំនេះត្រូវធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធាន **ម.ភ.ឆ.ភ.**។ ប្រធាននិងសមាជិកត្រូវមានសំឡេងក្នុងការបោះឆ្នោតលើរាល់បញ្ហាដែលតម្រូវឲ្យមានការអនុម័តពី **ម.ភ.ឆ.ភ.**។ ការអនុម័តនេះត្រូវផ្អែកលើសំឡេងភាគច្រើន ក្នុងករណីសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។ ការអនុម័តរបស់ **ម.ភ.ឆ.ភ.** យកជាការបានលុះត្រាតែមានវត្តមានប្រធានឬប្រធានស្តីទីដែលត្រូវបានចាត់តាំងដោយប្រធាននិងសមាជិក១(មួយ)រូបយ៉ាងតិច។

ប្រធាននិងសមាជិកទាំងអស់ត្រូវបានទទួលនូវសេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈនៃកិច្ចប្រជុំ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

សេចក្តីសម្រេចរបស់ **ទ.ក.ឆ.ក.** ត្រូវកត់ត្រាទុកក្នុងរបាយការណ៍នៃការប្រជុំ ដោយមានចុះហត្ថលេខារបស់ប្រធាន សមាជិកទាំងអស់ដែលបានចូលរួមប្រជុំ និងលេខាធិការនៃអង្គប្រជុំដែលត្រូវចាត់តាំងដោយប្រធាន។

មាត្រា ១៤.-

ដើម្បីធ្វើសេចក្តីសម្រេចណាមួយ ប្រធាននិងសមាជិកនៃ **ទ.ក.ឆ.ក.** ត្រូវធ្វើការពិចារណាឲ្យបានហ្មត់ចត់និងត្រឹមត្រូវលើបញ្ហាទាំងអស់ដែលពាក់ព័ន្ធឲ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលលើវិស័យទូរគមនាគមន៍ ។

រាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនេះត្រូវថែងលម្អិតក្នុងសេចក្តីប្រកាសជាសាធារណៈមួយធ្វើដោយ **ទ.ក.ឆ.ក.** នៅមុនពេលធ្វើសេចក្តីសម្រេចលើបទប្បញ្ញត្តិណាមួយនោះ។

មាត្រា ១៥.-

មុនពេលប្រកាសឲ្យប្រើបទបញ្ជាទូទៅ វិធានឬបទប្បញ្ញត្តិណាមួយ **ទ.ក.ឆ.ក.** ត្រូវជូនដំណឹងពីខ្លឹមសារនិងលក្ខខណ្ឌ ហើយត្រូវផ្តល់ឱកាសឲ្យនីតិបុគ្គលដែលពាក់ព័ន្ធនិងសាធារណជនបង្ហាញភស្តុតាងនិងបញ្ចេញមតិយោបល់។ **ទ.ក.ឆ.ក.** ត្រូវជូនដំណឹងសមស្របដល់នីតិបុគ្គលឬជននោះអំពីពេលវេលានិងទីកន្លែងសម្រាប់នីតិបុគ្គលនោះមានឱកាសផ្តល់ភស្តុតាងនិងបញ្ចេញមតិយោបល់។ រាល់បទបញ្ជា វិធាន និងបទប្បញ្ញត្តិទាំងនោះត្រូវផ្តល់ជូនដល់សាធារណជនមុនពេលដែល **ទ.ក.ឆ.ក.** ធ្វើការសន្និដ្ឋានចេញបទបញ្ជាឬសេចក្តីសម្រេចពាក់ព័ន្ធនីតិបុគ្គលឬជនណាមួយ ។

មាត្រា ១៦.-

បន្ទាប់ពី **ទ.ក.ឆ.ក.** ចេញសេចក្តីសម្រេចជាចុងក្រោយ នីតិបុគ្គលឬជនពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា។ ការប្តឹងតវ៉ានេះត្រូវអនុវត្តក្នុងរយៈពេល៩០(កៅសិប)ថ្ងៃបន្ទាប់ពីចេញសេចក្តីសម្រេចខាងលើ។

មាត្រា ១៧.-

ទ.ក.ឆ.ក. មានលេខាធិការដ្ឋានមួយជាសេនាធិការ។ លេខាធិការដ្ឋាននៃ **ទ.ក.ឆ.ក.** ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើអគ្គនាយកនិងអនុប្រធានមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការតាមការចាំបាច់។

ប្រធានត្រូវតែងតាំងដោយព្រះរាជក្រឹត្យនិងអនុប្រធានត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ទៅនាយករដ្ឋមន្ត្រី។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **ទ.ក.ឆ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា ១៨.-

ម.ក.ទ.ក. មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ក្នុងករណីចាំបាច់ **ម.ក.ទ.ក.** អាចជ្រើសរើសមន្ត្រីជាប់កិច្ចសន្យានិងជួលអ្នកឯកទេសផ្សេងទៀតតាមតម្រូវការចាំបាច់សម្រាប់អនុវត្តភារកិច្ចរបស់ខ្លួនបាន។ មន្ត្រីជាប់កិច្ចសន្យានិងអ្នកឯកទេសរបស់ **ម.ក.ទ.ក.** ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

ប្រាក់បៀវត្សរ៍និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីជាប់កិច្ចសន្យានិងអ្នកឯកទេសរបស់ **ម.ក.ទ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **ម.ក.ទ.ក.**។

មាត្រា ១៩.-

ម.ក.ទ.ក. មាននិមិត្តសញ្ញានិងត្រាដោយឡែករបស់ខ្លួន។

ជំពូកទី៥
ធនធាននិងថវិការបស់ ម.ក.ទ.ក.

មាត្រា ២០.-

ម.ក.ទ.ក. មានថវិកាស្វយ័តមួយសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ ថវិកានេះមានជាអាទិ៍ៈ

- ដើមទុនដែលរដ្ឋផ្តល់ឲ្យ(តុល្យការដំបូងនៅពេលបង្កើត)
- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យបន្ថែម
- កម្រៃដែលអ្នកសុំអាជ្ញាបណ្ណនិងអ្នកទទួលអាជ្ញាបណ្ណត្រូវបង់ព្រមទាំងកម្រៃផ្សេងៗតាមការកំណត់របស់ **ម.ក.ទ.ក.**
- ប្រាក់បានមកពីប្រភពជំនួយផ្សេងៗ។

ថវិការបស់ **ម.ក.ទ.ក.** ត្រូវតម្កល់ទុកក្នុងគណនីមួយនៅធនាគាររបស់រដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា។ មានតែ **ម.ក.ទ.ក.** ទេ ដែលមានសិទ្ធិប្រើប្រាស់ថវិកានេះ។

មាត្រា ២១.-

ម.ក.ទ.ក. ត្រូវបង្កើតគម្រោងថវិកាសម្រាប់កិច្ចប្រតិបត្តិការនៃការិយបរិច្ឆេទនីមួយៗដែលមានកំណត់ចំណូលនិងចំណាយរបស់ **ម.ក.ទ.ក.**។ គម្រោងថវិកាត្រូវកំណត់ឲ្យបានច្បាស់លាស់នូវកម្រៃអាជ្ញាបណ្ណនិងកម្រៃផ្សេងៗ សម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗរួមទាំងវិធីគណនាកម្រៃអាជ្ញាបណ្ណនិងកម្រៃផ្សេងៗព្រមទាំងបៀវត្សរ៍និងប្រាក់ចំណាយផ្សេងទៀតដែលត្រូវទូទាត់ជូនប្រធាន សមាជិក និងមន្ត្រីរបស់ **ម.ក.ទ.ក.** ។

ម.ក.ទ.ក. ត្រូវដាក់គម្រោងថវិកានេះជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចតាមសំណើរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កម្រៃអាជ្ញាបណ្ណនិងកម្រៃផ្សេងៗត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ក្នុងករណីមានសំណល់ថវិកានៅដំណាច់ឆ្នាំណាមួយ **ប.ភ.ឆ.ភ.** ត្រូវផ្ទេរសំណល់ថវិកានោះទៅប្រើប្រាស់សម្រាប់គម្រោងថវិកាឆ្នាំបន្ទាប់ទៀតស្របតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ចំពោះកង្វះថវិកាដូចមានចែងក្នុងកថាខណ្ឌខាងលើ **ប.ភ.ឆ.ភ.** ត្រូវកែសម្រួលកម្រៃអាជ្ញាបណ្ណនិង/ឬកម្រៃផ្សេងទៀតឡើងវិញសម្រាប់គម្រោងថវិកាឆ្នាំបន្ទាប់។

ក្នុងករណីកែសម្រួលកម្រៃអាជ្ញាបណ្ណនិង/ឬកម្រៃផ្សេងទៀតរហូតដល់កម្រិតអតិបរមារួចហើយ ប៉ុន្តែនៅតែពុំអាចទ្រទ្រង់កិច្ចប្រតិបត្តិការរបស់ខ្លួន **ប.ភ.ឆ.ភ.** ត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេចកម្រិតអតិបរមានៃកម្រៃអាជ្ញាបណ្ណនិង/ឬកម្រៃផ្សេងៗជាថ្មីឡើងវិញ។

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យរបស់ **ប.ភ.ឆ.ភ.** ត្រូវអនុវត្តតាមប្រព័ន្ធគណនេយ្យសាធារណៈនិងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

មាត្រា ២២.-

ប.ភ.ឆ.ភ. ត្រូវរៀបចំរបាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំឲ្យបានយ៉ាងយូរបំផុត៣០(សាមសិប)ថ្ងៃក្រោយឆ្នាំការិយបរិច្ឆេទ។

របាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំរួមទាំងសៀវភៅគណនីរបស់ **ប.ភ.ឆ.ភ.** និងកំណត់ហេតុពាក់ព័ន្ធត្រូវបានធ្វើសវនកម្ម។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរបន្ទាប់ពីធ្វើសវនកម្មរួចរបាយការណ៍ទាំងអស់នោះត្រូវដាក់ជូនទៅនាយករដ្ឋមន្ត្រីតាមរយៈក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយ **ប.ភ.ឆ.ភ.** ដើម្បីពិនិត្យ សម្រេច និងត្រូវផ្សព្វផ្សាយជាសាធារណៈ។

ជំពូកទី៦
អន្តរប្បញ្ញត្តិ

មាត្រា ២៣.-

សម្រាប់អាណត្តិដំបូង បន្ទាប់ពីព្រះរាជក្រឹត្យនេះចូលជាធរមានក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវស្នើសុំទៅនាយករដ្ឋមន្ត្រី ដើម្បីរៀបចំការតែងតាំងប្រធាន **ប.ភ.ឆ.ភ.** មួយរូបសម្រាប់អាណត្តិ៣(បី)ឆ្នាំនិងសមាជិក២(ពីរ)រូបទៀតដែលសមាជិកទីមួយមានអាណត្តិ២(ពីរ)ឆ្នាំនិងសមាជិកទីពីរមានអាណត្តិ១(មួយ)ឆ្នាំ ព្រមទាំងប្រធានលេខាធិការដ្ឋាននៃ **ប.ភ.ឆ.ភ.** មួយរូប។

មាត្រា ២៤.-

ក្នុងពេលចាប់ផ្តើមដំណើរការការងាររបស់ខ្លួន **ប.ភ.ឆ.ភ.** ត្រូវបានផ្តល់មូលនិធិដំបូងពីរាជរដ្ឋាភិបាល។ មូលនិធិនេះ ត្រូវដាក់តម្កល់ក្នុងគណនីមួយដោយឡែកនៅក្នុងធនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ការប្រើប្រាស់របស់ **ប.ភ.ឆ.ភ.**។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ២៥.-

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវផ្ទេរតួនាទីនិងភារកិច្ចទៅ **ប.ក.ឆ.ក.** ជាបណ្តើរៗ ស្របតាមព្រះរាជក្រឹត្យនេះ នៅពេល **ប.ក.ឆ.ក.** ចាប់ផ្តើមដំណើរការការងាររបស់ខ្លួន។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបន្តការប្រមូលចំណូលនិងបំណុលដូចមានចែងក្នុងមាត្រា២០នៃព្រះរាជក្រឹត្យនេះរហូតដល់ **ប.ក.ឆ.ក.** ចាប់ផ្តើមដំណើរការងាររបស់ខ្លួន។

ជំពូកទី៧
អវសានប្បញ្ញត្តិ

មាត្រា ២៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ លើកលែងតែព្រះរាជក្រឹត្យលេខ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិមួយសម្រាប់ទទួលបន្ទុករៀបចំនិងអភិវឌ្ឍគោលនយោបាយសម្រាប់រយៈពេលខ្លី មធ្យម និងវែង ដើម្បីជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យាហៅថា អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (National Information Communications Technology Development Authority) ត្រូវទុកជាធរមាន។

មាត្រា ២៧.-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩៣-១២០៣-១៥០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

លេខៈ ១៧៤ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មីនា ឆ្នាំ២០១២

អគ្គ[illegible]ការរងទី១រាជរដ្ឋាភិបាល

១២/១២

សយ សុខា

12/12

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភាឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក ដែលបានបង្កើតឡើងដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

មាត្រា ២.-

អនុក្រឹត្យនេះមានគោលដៅកំណត់ក្របខ័ណ្ឌគតិយុត្ត សម្រាប់ផ្តល់ធនធានហិរញ្ញវត្ថុមួយចំណែក ប្រកបដោយសមធម៌ ចីរភាព និងអាចព្យាករណ៍បានដល់រដ្ឋបាលក្រុង ស្រុក ដើម្បីជួយទ្រទ្រង់និងអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

មាត្រា ៣.-

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងមូលនិធិក្រុង ស្រុក ក្នុងការផ្តល់មូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌពីថវិកាជាតិ និងពីប្រភពផ្សេងៗទៀតសម្រាប់រួមចំណែកក្នុងការអនុវត្តចំណាយបម្រើឱ្យសកម្មភាពទាំងឡាយដូចតទៅ ៖

- ការបំពេញភារកិច្ចតាមផ្លូវច្បាប់
- ការបំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា។

ជំពូកទី២

ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិក្រុង ស្រុក

មាត្រា ៤.-

ប្រភពធនធាននៃមូលនិធិក្រុង ស្រុករួមមាន ៖

- ការចូលរួមចំណែកពីចំណូលចរន្តនៃថវិការដ្ឋ
- ការរួមចំណែកពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការ និង
- ការចូលរួមធនធានពីប្រភពផ្សេងៗទៀតដែលកំណត់ដោយច្បាប់ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

មាត្រា ៥.-

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុកត្រូវកំណត់សម្រាប់ថេរៈវេលាចំនួនបីឆ្នាំ

លើមូលដ្ឋានក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃថវិកាទូទៅរបស់រដ្ឋ។

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុក សម្រាប់ឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ មានដូចខាងក្រោម៖

- សម្រាប់ឆ្នាំថវិកា២០១២មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១១
- សម្រាប់ឆ្នាំថវិកា២០១៣ មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលនឹងត្រូវអនុម័តនៅឆ្នាំ២០១២ និង
- សម្រាប់ឆ្នាំថវិកា២០១៤ មានចំនួន០,៨០ភាគរយនៃចំណូលចរន្តថវិកាជាតិដែលនឹងត្រូវអនុម័តនៅឆ្នាំ២០១៣។

មាត្រា ៦.-

ក្នុងករណីមានការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ ឬស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ឬសប្បុរសជននានាតាមរយៈប្រព័ន្ធថវិការដ្ឋដើម្បីជួយទ្រទ្រង់ការអភិវឌ្ឍមូលដ្ឋានក្រុង ស្រុក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចាត់នីតិវិធីបង់ចំណូលថវិការដ្ឋតាមរយៈរតនាគារជាតិគ្រង់តែម្តង។ ព្រមជាមួយនេះ ឥណទានបន្ថែមដែលមានទឹកប្រាក់ដូចគ្នាទៅនឹងចំណូលដែលបានបង់ចូលថវិការដ្ឋនេះ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវបានផ្ទេរចូលគណនីដោយឡែកនៃមូលនិធិក្រុង ស្រុក តាមរយៈអាណត្តិឧបត្ថម្ភកធនស្របតាមគោលដៅរបស់ភាគី ឬដៃគូអភិវឌ្ឍន៍។

មាត្រា ៧.-

ធនធាននៃមូលនិធិក្រុង ស្រុកត្រូវបានចាត់ចែង និងគ្រប់គ្រងតាមរយៈគណនីដោយឡែកមួយនៅរតនាគារជាតិ។ គណនីនេះត្រូវឆ្លុះបញ្ចាំងនូវរាល់ប្រតិបត្តិការចំណូលដែលបានមកពីគ្រប់ប្រភពធនធានទាំងអស់នៃមូលនិធិក្រុង ស្រុក ដូចបានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ និងប្រតិបត្តិការចំណាយដែលបានផ្ទេរពីមូលនិធិក្រុង ស្រុកប្រចាំឆ្នាំសម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលក្រុង ស្រុកនីមួយៗដូចបានកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ។

សមតុល្យចុងឆ្នាំនៃគណនីមូលនិធិក្រុង ស្រុកត្រូវបានយោងទៅដើមឆ្នាំបន្ទាប់។

មាត្រា ៨.-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគ្រប់គ្រងមូលនិធិក្រុង ស្រុក និងមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំវិភាជន៍ធនធានមូលនិធិក្រុង ស្រុកជូនដល់រដ្ឋបាលក្រុង ស្រុកនីមួយៗដូចដែលបានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ
- ជូនដំណឹងដល់រដ្ឋបាលក្រុង ស្រុកអំពីចំនួនធនធានមូលនិធិក្រុង ស្រុកដែលត្រូវទទួលបានពីការវិភាជន៍ប្រចាំឆ្នាំមុនពេលរៀបចំថវិកា និងធនធានមូលនិធិដែលរដ្ឋបាលក្រុង ស្រុកត្រូវទទួលបានពីការវិភាជន៍សម្រាប់រយៈពេលមធ្យម និង

- រៀបចំរបាយការណ៍នៃការអនុវត្តមូលនិធិក្រុង ស្រុក ប្រចាំខែ ប្រចាំត្រីមាសនីមួយៗ និងប្រចាំឆ្នាំនៃការអនុវត្តមូលនិធិក្រុង ស្រុក ជូនរាជរដ្ឋាភិបាលតាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

មាត្រា ៩.-

ក្រោយពីបានសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវ ៖

- ពិនិត្យ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីការផ្លាស់ប្តូរនានា ដែលត្រូវកែសម្រួលពាក់ព័ន្ធនឹងគោលបំណង វិធាន និងគោលការណ៍ផ្សេងៗនៃមូលនិធិក្រុង ស្រុក
- ផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីកម្រិតជាភាគរយនៃចំណែកចូលរួមពីថវិការដ្ឋទៅក្នុងធនធានមូលនិធិក្រុង ស្រុក
- កំណត់គោលដៅនានាដើម្បីកៀរគរធនធានពីខាងក្រៅចូលក្នុងធនធានមូលនិធិក្រុង ស្រុក
- កំណត់រូបមន្ត លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រជាក់លាក់ ដើម្បីបែងចែកធនធាននៃមូលនិធិក្រុង ស្រុក
- អនុញ្ញាតឱ្យមានការវាយតម្លៃឯករាជ្យលើការអនុវត្តមូលនិធិក្រុង ស្រុក ដោយអាជ្ញាធរសវនកម្មមានសមត្ថកិច្ច
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីដំណើរការមូលនិធិក្រុង ស្រុករៀងរាល់៦ខែ
- ធ្វើកិច្ចអន្តរាគមន៍លើការផ្ទេរធនធានមូលនិធិក្រុង ស្រុកក្នុងករណីចាំបាច់។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងតំណាងក្រុមប្រឹក្សាក្រុង ស្រុកត្រូវពិភាក្សាពិគ្រោះយោបល់នូវរាល់បញ្ហាពាក់ព័ន្ធនឹងគោលនយោបាយ និងប្រតិបត្តិផ្សេងៗលើការអនុវត្តមូលនិធិក្រុង ស្រុក។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវសម្របសម្រួលជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីកំណត់នីតិវិធីនិងបែបបទលើការជ្រើសរើសតំណាងក្រុមប្រឹក្សាក្រុង ស្រុក និងចូលរួមពិភាក្សាពិគ្រោះយោបល់ក្នុងការរៀបចំគោលនយោបាយដែលពាក់ព័ន្ធដល់ការអនុវត្តមូលនិធិក្រុង ស្រុក។

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវមានតួនាទីជាអ្នកទទួលខុសត្រូវផ្ទាល់ ក្នុងការជួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃមាត្រានេះ។

មាត្រា ១០.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវ ៖

- តាមដានការអនុវត្តរបស់រដ្ឋបាលក្រុង ស្រុកលើការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក
- រាយការណ៍ជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លើការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុកដោយរដ្ឋបាលក្រុង ស្រុក
- ស្នើកិច្ចអន្តរាគមន៍ពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការផ្ទេរធនធានមូលនិធិក្រុង ស្រុកទៅឱ្យរដ្ឋបាលក្រុង ស្រុកក្នុងករណីចាំបាច់។

ជំពូកទី៣
ការបែងចែក ការផ្ទេរ និងការប្រើប្រាស់ធនធានមូលនិធិក្រុង ស្រុក

មាត្រា ១១.-

ធនធានដែលវិភាជន៍ប្រចាំឆ្នាំទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវផ្អែកតាមរូបមន្តសមស្របដើម្បីធានាសមធម៌ និងប្រកបដោយតម្លាភាព។ លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រដែលប្រើក្នុងរូបមន្តដើម្បីវិភាជន៍ធនធាន ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយជាសាធារណៈ។ ធនធានមូលនិធិដែលបានវិភាជន៍ទៅឱ្យរដ្ឋបាលក្រុង ស្រុក គឺជាចំណែកមួយនៃគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

លក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រខាងលើនេះ ត្រូវបានកំណត់សម្រាប់រយៈពេលយ៉ាងតិចបីឆ្នាំ។ ការកែសម្រួលលក្ខណៈវិនិច្ឆ័យ និងប៉ារ៉ាម៉ែត្រត្រូវតែធ្វើឡើងដោយផ្អែកតាមលក្ខណៈបច្ចេកទេសសមស្រប ឬក្រោមហេតុផលនៃយុត្តិកម្មគោលនយោបាយ ដើម្បីធានាបាននូវសមធម៌នៃការវិភាជន៍ធនធានដល់រដ្ឋបាលក្រុង ស្រុកនីមួយៗ។

មាត្រា ១២.-

ធនធានមូលនិធិក្រុង ស្រុក ត្រូវចែកចេញជាពីរសមាសភាគដូចខាងក្រោម ៖

- សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និង
- សមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។

ទំហំធនធាននៃសមាសភាគនីមួយៗនៃមូលនិធិក្រុង ស្រុកត្រូវកំណត់ដូចខាងក្រោម ៖

ក). ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ ត្រូវបានកំណត់ដោយផ្អែកលើឯកតា រង្វាស់ និងនិយាមដូចខាងក្រោម ៖

- ចំនួនសរុបនៃសមាជិកក្រុមប្រឹក្សាក្រុងស្រុក និងប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក
- ចំនួនសរុបនៃអភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក និងប្រាក់បៀវត្សសម្រាប់ប្រភេទនីមួយៗ និង

- គម្រោងចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗទៀត មិនឱ្យលើសពី២៨ភាគរយនៃធនធានមូលនិធិសរុប *ដក* ចំនួនសរុបប្រាក់ឧបត្ថម្ភរបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងប្រាក់បៀវត្សរបស់អភិបាល អភិបាលរង និងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក។

ខ). ទំហំធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ស្មើនឹងធនធានវិភាជន៍សរុប *ដក* ទំហំធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ។

មាត្រា ១៣.-

ធនធាននៃសមាសភាគទាំងពីរនៃមូលនិធិក្រុង ស្រុក ត្រូវបានបែងចែកទៅរដ្ឋបាលក្រុង ស្រុកនីមួយៗ ស្របតាមវិធានដូចខាងក្រោម ៖

១. ធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅត្រូវបានវិភាជន៍ទៅរដ្ឋបាលក្រុង ស្រុកនីមួយៗ ដោយអនុលោមតាមនិយាមដូចខាងក្រោម ៖

ក). ចំណាយប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សាក្រុង ស្រុក

ខ). ចំណាយប្រាក់បៀវត្សរបស់អភិបាល អភិបាលរងនៃគណៈអភិបាលក្រុង ស្រុក

គ). ចំណាយប្រាក់បៀវត្សរបស់បុគ្គលិករដ្ឋបាលក្រុង ស្រុក ផ្អែកតាមចំនួនបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដែលកំណត់ដោយក្រសួងមហាផ្ទៃ

ឃ). ធនធានសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗត្រូវបែងចែកទៅរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖

- ចំណែកស្មើគ្នាមានចំនួន៤០ភាគរយ ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ
- សមាជិកក្រុមប្រឹក្សាមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាជិកក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- គណៈអភិបាលមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនសមាសភាពគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ
- មន្ត្រីបុគ្គលិកមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនមន្ត្រីបុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ។

២. ធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានត្រូវបានវិភាជន៍ទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗតាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម ៖

ក). ចំណែកស្មើគ្នាជាមូលដ្ឋានមានចំនួន៤០ភាគរយ ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាលក្រុង ស្រុកនីមួយៗ

ខ). ប្រជាពលរដ្ឋមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាជន

នៃរដ្ឋបាលក្រុង ស្រុកនីមួយៗ ដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ

គ). សន្ទស្សន៍ភាពក្រីក្រមានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងផែនការ និង

ឃ). ឃុំ សង្កាត់មានចំនួន២០ភាគរយ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុកនីមួយៗដោយផ្អែកតាមទិន្នន័យផ្លូវការរបស់ក្រសួងមហាផ្ទៃ។

លក្ខណៈវិនិច្ឆ័យ និងចំនួនភាគរយនៃសន្ទស្សន៍នីមួយៗសម្រាប់ធ្វើការបែងចែកធនធានឱ្យសមាសភាគអភិវឌ្ឍន៍មូលដ្ឋានអាចត្រូវបានពិនិត្យ និងកែលម្អឡើងវិញនាពេលមួយសមស្របដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រា១១នៃអនុក្រឹត្យនេះ។

មាត្រា ១៤.-

រដ្ឋបាលក្រុង ស្រុកអាចប្រើប្រាស់ធនធានដែលផ្ទេរពីមូលនិធិក្រុង ស្រុកដើម្បីផ្តល់ហិរញ្ញប្បទានដល់ចំណាយ ចំណែកណាមួយដូចខាងក្រោមនេះបាន លុះត្រាតែចំណាយទាំងនោះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិកាក្រុង ស្រុកដែលបានអនុម័ត និងមិនផ្ទុយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងច្បាប់និងលិខិតបទដ្ឋាននានាដទៃទៀតដែលមានជាធរមាន។

១. ការប្រើប្រាស់ធនធានមូលនិធិនៃសមាភាគរដ្ឋបាលទូទៅ ៖

ក). ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងកិច្ចប្រតិបត្តិការរដ្ឋបាលក្រុង ស្រុក

ខ). ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងកិច្ចអភិវឌ្ឍន៍ ឬលទ្ធកម្មលើអចលនទ្រព្យ ដូចជាអគារ បរិក្ខារការិយាល័យ គ្រឿងសង្ហារិម មធ្យោបាយដឹកជញ្ជូនសម្រាប់ប្រើប្រាស់ក្នុងបុព្វហេតុរដ្ឋបាល។

២. ការប្រើប្រាស់ធនធានមូលនិធិនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ៖

ក). ចំណាយចរន្តទាំងឡាយដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាមូលដ្ឋាន កិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននិងបរិក្ខារផ្សេងៗទៀតដែលត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់សេវាទាំងនោះ។

ខ). ចំណាយមូលធនដែលពាក់ព័ន្ធទៅនឹងការវិនិយោគក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន។

មាត្រា ១៥.-

ផ្អែកលើមូលនិធិដែលត្រូវផ្ទេរប្រចាំឆ្នាំទៅឱ្យរដ្ឋបាលក្រុង ស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការបោះផ្សាយអាណត្តិផ្ទេរពីគណនីថវិការដ្ឋ ទៅគណនីដោយឡែករបស់មូលនិធិក្រុង ស្រុកនៅរតនាគារជាតិតាមការកំណត់ដូចខាងក្រោម ៖

- ៥០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែឧសភា
- ៨០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែសីហា

- ១០០ភាគរយនៃមូលនិធិសរុបយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែតុលា។

ការផ្ទេរធនធានមូលនិធិក្រុង ស្រុកជូនទៅរដ្ឋបាលក្រុង ស្រុកនីមួយៗត្រូវធ្វើឡើងជាបួនដំណាក់កាល ដោយកំណត់ប្រចាំត្រីមាសនីមួយៗ។ នៅដើមត្រីមាសទី១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបញ្ជាផ្ទេរចំណាយ ចំនួនមួយភាគបួន(១/៤)នៃមូលនិធិប្រចាំឆ្នាំរបស់ក្រុងស្រុកនីមួយៗដោយស្វ័យប្រវត្តិ។ ដោយឡែកសម្រាប់ត្រីមាសទី២ ទី៣ និងទី៤ រដ្ឋបាលក្រុង ស្រុកត្រូវធ្វើសំណើសុំផ្ទេរមូលនិធិមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ នៅដើមខែទីបីនៃត្រីមាសមុន ដើម្បីធ្វើការផ្ទៀងផ្ទាត់ល័ក្ខខ័ណ្ឌនានានៃការផ្ទេរធនធានមូលនិធិក្រុង ស្រុកដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណូល ចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងរបាយការណ៍ប៉ាន់ស្មានអនុវត្តចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់ដោយមានឯកសារគាំទ្រជាមូលដ្ឋាន។

នីតិវិធីក្នុងការផ្ទៀងផ្ទាត់នៃការបំពេញល័ក្ខខ័ណ្ឌសម្រាប់ការផ្ទេរទម្រង់របាយការណ៍ចំណូល ចំណាយថវិកាដែលបានអនុវត្តនៅត្រីមាសមុនៗ និងទម្រង់របាយការណ៍ប៉ាន់ស្មានអនុវត្តចំណូល ចំណាយថវិកាសម្រាប់ត្រីមាសបន្ទាប់ និងឯកសារគាំទ្រជាមូលដ្ឋានខាងលើនេះត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ជំពូកទី៤
អន្តរប្បញ្ញត្តិ

មាត្រា ១៦.-

នៅក្នុងឆ្នាំ២០១២ ក្នុងករណីដែលរដ្ឋបាលក្រុង ស្រុកពុំទាន់មានថវិកាផ្ទាល់របស់ខ្លួន ការផ្ទេរមូលនិធិទៅឱ្យក្រុង ស្រុកនីមួយៗត្រូវបានកត់ត្រានៅក្នុងគម្រោងថវិការបស់ខេត្តសាមីដោយលម្អិតទៅតាមក្រុង ស្រុកនីមួយៗ និងត្រូវបានអភិបាលនៃគណៈអភិបាលខេត្តធ្វើប្រតិភូកម្មជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុកនីមួយៗ ជាអាណាប័កផ្ទេរសិទ្ធិទាំងចំណូល ទាំងចំណាយនៅពេលដំណើរការអនុវត្តថវិកាដែលមានគណនីប្រាក់បញ្ញើថវិកាដោយឡែកពីគណនីប្រាក់បញ្ញើថវិការបស់ខេត្តសាមី។

នៅក្នុងឆ្នាំ២០១២ ប្រសិនបើមានការចូលរួមធនធានពីដៃគូអភិវឌ្ឍន៍ទៅក្នុងមូលនិធិក្រុង ស្រុកធនធាននោះនឹងត្រូវបានវិភាជន៍ និងផ្ទេរជូនក្រុង ស្រុកត្រង់ចូលទៅគណនីប្រាក់បញ្ញើថវិការបស់រដ្ឋបាលក្រុង ស្រុកដើម្បីអនុវត្តដោយផ្ទាល់តែម្តង។

ជំពូកទី៥
អវសានប្បញ្ញត្តិ

មាត្រា ១៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ១៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក និងអភិបាលក្រុង ស្រុកទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១០រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនយ៉ាងច្រើន ចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តនិគ្រោធវ័ន ហៅវត្តគល់ទទឹង សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

១-លោក លឹម ម៉េងជាវ សប្បុរសជន

២-ឧបាសិកាភាំង ហ្គិចណៃ សប្បុរសជន

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:

១-លោក ឈឹម រិទ្ធ សប្បុរសជន

២-លោក ចាន់ សារិទ្ធ សប្បុរសជន

៣-លោក ឈឹម រិន សប្បុរសជន

៤-លោក ឈូ គីមសាន សប្បុរសជន

៥-ឧបាសកថោង ប៊ុនធឿន អាចារ្យវត្ត

៦-លោក អ៊ួន សុខហេង សប្បុរសជន

៧-ឧបាសិកាគ្រៀល ស៊ីយ៉ា សប្បុរសជន

៨-ឧបាសិកាអ៊ុន ពូន សប្បុរសជន

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរិទ្ធិ:

១-អ្នកស្រី	**យ៉ាវ នាង**	សប្បុរសជន
២-ឧបាសិកា	**ទ៉ា គីមហោ**	សប្បុរសជន
៣-ឧបាសក	**ឈៀ គុន**	គណៈកម្មការវត្ត
៤-លោក	**ឈឹម ជាង**	សប្បុរសជន
៥-លោក	**ឡុង បូណា**	សប្បុរសជន
៦-ឧបាសិកា	**ពឹង អាយទីម**	សប្បុរសជន

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ.២៣៥..អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន១២រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងអភិវឌ្ឍន៍ ភូមិ ឃុំ ស្រុក មួយចំនួនក្នុងខេត្តព្រះសីហនុ ដូចមានរាយនាមខាងក្រោម ៖

១-លោកជំទាវ	**នួច**	**ភាណ្ណារ៉ា**	ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
២-លោក	**ស្វាយ**	**ឌឿន**	ជំនួយការឯកឧត្តម **សៀង សារ៉ាត** អភិបាលខេត្តព្រះសីហនុ
៣-លោក	**ព្រាប**	**សំផុន**	ប្រធានការិយាល័យបុគ្គលិក សាលាខេត្តព្រះសីហនុ
៤-លោក	**ប្រាក់**	**សុវណ្ណ**	ប្រធានការិយាល័យគ្រប់គ្រងការអភិវឌ្ឍន៍ និងសំណង់ ខេត្តព្រះសីហនុ
៥-លោក	**ផុង**	**គា**	មេឃុំកំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ
៦-លោក	**ឆៅ**	**ថន**	ប្រធានការិយាលយអប់រំ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ
៧-លោក	**សួន**	**នីយ**	សមាជិកក្រុមប្រឹក្សាឃុំចំការហ្លួង ស្រុកកំពង់សីលា ខេត្តព្រះសីហនុ
៨-លោក	**ហួន**	**ដារ៉ា**	សប្បុរសជន
៩-លោក	**ម៉េង**	**ហុង**	គណៈកម្មការវត្តស្ទឹងឆាយ
១០-លោក	**ម៉ឿង**	**សៅ**	សប្បុរសជន
១១-ឧបាសិកា	**សុខ**	**គាន**	សប្បុរសជន
១២-ឧបាសិកា	**សេង**	**សាត់**	គណៈកម្មការវត្តស្ទឹងឆាយ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ... ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនមន្ត្រីរាជការ ចំនួន២១រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោក **អ៊ុច ចាន់នី** ភ្នាក់ងារទីស្នាក់ការគយ និងរដ្ឋាករកែវផុស

២-លោកស្រី **យ៉េម សំអាង** មន្ត្រី ពិធីការ សាលាខេត្តព្រះសីហនុ

៣-លោក **នៅ ធី** មន្ត្រីភូមិបាល រៀបចំដែនដី នគរូបនីយកម្មសំណង់ និងភូមិបាល ស្រុកស្រែអំបិល

៤-លោក **ចាន់ ធឿន** ភ្នាក់ងារទីស្នាក់ការគយ និងរដ្ឋាករកែវផុស

៥-លោក **តែម មុនីបុត្រ** ភ្នាក់ងារទីស្នាក់ការគយ និងរដ្ឋាករកែវផុស

៦-លោក **ឆោម ប៊ុនធឿន** ភ្នាក់ងារទីស្នាក់ការគយ និងរដ្ឋាករកែវផុស

៧-លោក **តែម សុទ្ធសុធី** ភ្នាក់ងារទីស្នាក់ការគយ និងរដ្ឋាករកែវផុស

៨-អនុនាវីទោ **ចិន សំអឿន** អត្តលេខ ១៨៧៤៩៤ ជំនួយការគ្រឿងចក្រ ក៤ កងពលតូច ៣១ ជើងទឹក

៩-លោកស្រី **ញ៉ៀម លីណា** មន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

១០-លោក **សួន សុគី** ភ្នាក់ងារទីស្នាក់ការគយ និងរដ្ឋាករកែវផុស

១១-អនុសេនីយ៍ទោ **កែវ គិរុណា** អត្តលេខ ១៨២៣១ នាយផ្នែកសណ្តាប់ធ្នាប់សាធារណៈនគរបាល ស្រុកកំពង់សីលា ខេត្តព្រះសីហនុ

១២-លោក	**សុន**	**សុវណ្ណារ៉ា**	សប្បុរសជន
១៣-លោក	**ទុយ**	**សុវណ្ណារិន**	ប្រធានសង្កាត់រដ្ឋបាលព្រៃឈើ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ
១៤-លោក	**ហុក**	**ចោយ**	នាយកសាលាបឋមសិក្សា ភូមិតិរីវ័ន្ត ឃុំស្ទឹងឆាយ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ
១៥-អនុសេនីយ៍ទោ	**អៀម**	**ដា**	អត្តលេខ ២៣៧១៥ នាយប៉ុស្តិ៍រដ្ឋបាល នគរបាល ឃុំចំការហ្លួង ស្រុកកំពង់សីលា ខេត្តព្រះសីហនុ
១៦-លោកស្រី	**ឈុន**	**សុភាព**	ប្រធានលទ្ធកម្ម សាលាខេត្តព្រះសីហនុ
១៧-លោក	**តាំង**	**ហេងហួ**	ប្រធានគណៈកម្មការ វត្តស្ទឹងឆាយ
១៨-លោក	**ស៊ុន**	**សុផាត**	អាចារ្យវត្តស្ទឹងឆាយ
១៩-លោក	**ឌុក**	**សាវ៉ាន់**	អាចារ្យវត្តស្ទឹងឆាយ
២០-អ្នកគ្រូ	**គុណា**	**ដាណា**	សាលារៀនបឋមសិក្សា ភូមិព្រៃប្រសិទ្ធ ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា
២១-អនុសេនីយ៍ត្រី	**ហេង**	**ទូច**	អត្តលេខ ១៨២២៨ នាយរងផ្នែកសេនាធិការនគរបាលស្រុកកំពង់សីលា

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនក្រុមការងារមូលនិធិបាយ័ន ចំនួន ២៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញការងារ នៃកម្មវិធី នេះមិនមែនជាសុបិន ផ្ទះទេវតា និង សុខភាពប្រជាជន សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

១- លោកវេជ្ជបណ្ឌិត នាង ប៊ុនសុផល្លី
២- លោកវេជ្ជបណ្ឌិត សុខ ប៊ុនចាន់
៣- លោកវេជ្ជបណ្ឌិត ខិត សុខលី
៤- លោកវេជ្ជបណ្ឌិត លី សុខខី
៥- លោកស្រីវេជ្ជបណ្ឌិត ឯក ឆវីវណ្ណា
៦- លោក ជា វណ្ណរិទ្ធ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

១- លោក យិន ខេមរា
២- លោក ជេត យ៉ុន
៣- លោក អេង រិទ្ធី
៤- អ្នកនាង ស៊ឹម សូលីកា
៥- លោក ទូច សាឯម
៦- លោក នង គន្ធាវី
៧- លោក ហែម រិទ្ធី

៨- លោក ជិន ប៊ុនធឿន
៩- លោក សៅ តិរុណា

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១- អ្នកស្រី ម៉ា ស្រីណា
២- លោកស្រី ប្រាក់ សុខាយុ
៣- លោក ធី សុផាន់ណា
៤- លោក ឯក សុភា
៥- លោក ចាន់ មុនីរ៉េត
៦- លោកស្រី រ៉ំ ពុទ្ធារិទ្ធ
៧- កញ្ញា គីម សុបញ្ញា
៨- កញ្ញា សុខ ស្រីលក្ខំណា
៩- លោក កង ប្រាក់
១០- លោក ស៊ុន និជា

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៥៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការសម្រួលភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានសម្រួលភារកិច្ចលោក **ឈូក បណ្ឌិត** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ១០ ពីអភិបាលក្រុងបាវិត នៃខេត្តស្វាយរៀង ឱ្យមកបម្រើការងារនៅសាលាខេត្តស្វាយរៀង ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៦០ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ៦០៨ គ្រឿង ជូននាយទាហាន នាយទាហានរង នៃកងយោធពលខេមរភូមិន្ទ ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិទទួលបានលទ្ធផលល្អ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១-វរសេនីយ៍ទោ	**ម៉ឹន ណាន់**	អត្តលេខ ០០៣៥៤៨	នាយរង មណ្ឌល៥ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
២-វរសេនីយ៍ទោ	**ឆាត់ ធីរៈ**	អត្តលេខ ០០៣៥៤៩	នាយរង មណ្ឌល ៥ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៣-វរសេនីយ៍ទោ	**គេច សុខុន**	អត្តលេខ ០០៣៥៤៤	នាយរង មណ្ឌល ៥ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៤-វរសេនីយ៍ទោ	**តូច សេង**	អត្តលេខ ០១០២២៨	នាយក្រុម ប្រតិ.ក្រុងប៉ៃលិន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៥-វរសេនីយ៍ទោ	**អ៊ឹម ចន្ថា**	អត្តលេខ ០១៨៧០៧	នាយរង មណ្ឌល ២ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៦-វរសេនីយ៍ទោ	**ស្ងួន យ៉ុគ**	អត្តលេខ ០១០១៩០	នាយរង មណ្ឌល ២ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧- វរសេនីយ៍ទោ	**សុខ គឹមស៊ឿន**	អត្តលេខ ០១៨៧៣៨	នាយក្រុមប្រតិ.ខេត្តបន្ទាយមានជ័យ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨-វរសេនីយ៍ត្រី	**ម៉ុំ គឹមសាន្ត**	អត្តលេខ ០១៨៨៦០	នាយរង មណ្ឌល ៥ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩-វរសេនីយ៍ត្រី	**លាង ពិសិដ្ឋ**	អត្តលេខ ០១០២២៩	នាយក្រុម ប្រតិ.ខេត្តពោធិសាត់ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០-វរសេនីយ៍ត្រី	**ស៊ិន ទិចិត្រ**	អត្តលេខ ០១០២៣៩	នាយរង មណ្ឌល ២ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១១-វរសេនីយ៍ត្រី	**ព្រហ្ម អាន**	អត្តលេខ ០១៨៧៣៩	នាយក្រុម ប្រតិ.ខេត្តកំពង់ចាម នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១២-វរសេនីយ៍ត្រី	**ហ៊ុយ សំតាន់**	អត្តលេខ ០១៨៨៨៤	នាយរង ក្រុម ប្រតិ.ខេត្តកំពង់ចាម នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៣-វរសេនីយ៍ត្រី	**ចាប គឿន**	អត្តលេខ ០១៨៨៨៩	នាយក្រុមប្រតិបត្តិការច្រកតាទុំ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៤-វរសេនីយ៍ត្រី	**តុង ទាសនា**	អត្តលេខ ០២៨១២០	នាយក្រុមប្រតិ.ច្រកកំពង់ស្ពាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥-វរសេនីយ៍ត្រី	**ម៉ិន ប៉ុម**	អត្តលេខ ០១៨៩៨២	នាយផ្នែក ផែនការសរុប នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦-វរសេនីយ៍ត្រី	**ឈ្លាង ម៉ុំ**	អត្តលេខ ០១៨៧៦០	នាយផ្នែក ការពារសម្ងាត់ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៧-វរសេនីយ៍ត្រី	**ផន ផល្លី**	អត្តលេខ ០១៨៨៩៥	នាយផ្នែក ស៊ើបអង្កេត នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៨-វរសេនីយ៍ត្រី	**ភូប ម៉ាត់**	អត្តលេខ ០១៨៧៧៩	ជំនួយការ នាយកដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៩-វរសេនីយ៍ត្រី	**ពៅ សុខហេង**	អត្តលេខ ០១៨៨២៣	ជំនួយការ នាយកដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២០-វរសេនីយ៍ត្រី **ខៀវ លុច្ស** អត្តលេខ ០០៣៥៧៦ ជំនួយការ ការិ.ប្រតិ.ក្រៅប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២១-វរសេនីយត្រី **ហឹ អូន** អត្តលេខ ០១៨៧៣០ ជំនួយការមណ្ឌល៣ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២២-វរសេនីយត្រី **ឌី មូ** អត្តលេខ ០១៨៧៩៨ នាយ ក្រុម ប្រតិ.ខេត្តតាកែវ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២៣-វរសេនីយត្រី **ខៀវ ម៉ារីន** អត្តលេខ ០២៨០៩១ នាយរង ក្រុម ប្រតិ.ខេត្តតាកែវ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២៤-វរសេនីយត្រី **ហ៊ុយ ម៉ុនធឿន** អត្តលេខ ០២៨២៩៣ នាយក្រុម ប្រតិ.ច្រកកំពង់ក្រសាំង នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២៥-វរសេនីយ៍ត្រី **គឹម សឿន** អត្តលេខ ០១៨៨៥៧ នាយរង ក្រុមប្រតិ.ខេត្តកំពង់ស្ពឺ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២៦-វរសេនីយ៍ត្រី **គឹម ហៃ** អត្តលេខ ០១៨៧៦៩ នាយរង ក្រុមប្រតិ.ខេត្តកំពង់ស្ពឺ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២៧-វរសេនីយ៍ត្រី **ឡោ ម៉ុនហុក** អត្តលេខ ០១៨៨៥៨ នាយក្រុម ប្រតិ.ច្រកអណ្តូងទឹក នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២៨-វរសេនីយ៍ត្រី **កែវ សុវណ្ណារិទ្ធ** អត្តលេខ ០១៨៨៤៧ នាយក្រុមប្រតិបត្តិការច្រកកែវជុស នាយកដ្ឋានស្រាវជ្រាវចារកិច្ច

២៩-វរសេនីយ៍ត្រី **កៅ ស៊ីណា** អត្តលេខ ០២៨០៩៩ នាយក្រុមប្រតិ.ច្រកកំពង់ផែអន្តរជាតិ ខេត្តព្រះសីហនុ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣០-វរសេនីយ៍ត្រី **ម៉ុម នីតូ** អត្តលេខ ០១៨៨៦៦ នាយរង ក្រុម ប្រតិ.ខេត្តកំពត នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣១-វរសេនីយ៍ត្រី **អ៊ី សារឿន** អត្តលេខ ០១៨៧២៨ នាយ ច្រក តាកែនកោះស្លា នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣២-វរសេនីយ៍ត្រី **វេជ្ជ មុន្នី** អត្តលេខ ០១៨៩១១ នាយរងក្រុម ប្រតិ.ខេត្តកំពង់ឆ្នាំង នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣៣-វរសេនីយ៍ត្រី **អៀម ឈុំ** អត្តលេខ ០១៨៩១២ នាយរងក្រុម ប្រតិ.ខេត្តកំពង់ឆ្នាំង នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣៤-វរសេនីយ៍ត្រី **ឡាយ ចាន់តារា** អត្តលេខ ០១៨៩៤១ នាយរង ក្រុមប្រតិបត្តិការកណ្តាល នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣៥-វរសេនីយ៍ត្រី **ព្រហ្ម សារ៉ន** អត្តលេខ ០១៨៧៣៥ នាយរង ក្រុមប្រតិបត្តិការកណ្តាល នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣៦-វរសេនីយ៍ត្រី **ឃូ ហៃ** អត្តលេខ ០១៨៨៩៣ នាយរង ក្រុមប្រតិបត្តិការកណ្តាល
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣៧-វរសេនីយ៍ត្រី **និន តិចឡុង** អត្តលេខ ០២២៤២៧ នាយច្រកបារិត
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៣៨-វរសេនីយ៍ត្រី **ព្រហ្ម ខឿន** អត្តលេខ ០១០៣៧០ នាយលេខាធិការដ្ឋាន
សាលាពលទាហាន យោធភូមិភាគពិសេស

៣៩-វរសេនីយ៍ត្រី **អ៊ូ សុខឿន** អត្តលេខ ០១១៣៤៩ នាយហ្វឹកហ្វឺនសាលាពលទាហាន
យោធភូមិភាគពិសេស

៤០-វរសេនីយ៍ត្រី **សោម សារ៉ុម** អត្តលេខ ០១៥២៩៣ នាយចាត់ការទូទៅ សាលាពលទាហាន
យោធភូមិភាគពិសេស

៤១-វរសេនីយ៍ត្រី **គួន ចណ្ណះ** អត្តលេខ ០១៥២៥៤ ជំនួយការការិយាល័យទី៥
យោធភូមិភាគពិសេស

៤២-វរសេនីយ៍ត្រី **ឈួន សុផល** អត្តលេខ ០១៥២៣៦ ជំនួយការការិយាល័យទី៣
យោធភូមិភាគពិសេស

៤៣-វរសេនីយ៍ត្រី **សី ហឿន** អត្តលេខ ០២៧៧៦៧ នាយរងការិយាល័យអភិវឌ្ឍន៍
យោធភូមិភាគពិសេស

៤៤-វរសេនីយ៍ត្រី **ឌី ធារិទ្ធ** អត្តលេខ ០១៥១៩៩ នាយរងផ្នែកបញ្ជូនសារ
យោធភូមិភាគពិសេស

៤៥-វរសេនីយ៍ត្រី **ឃ្លោក លឿន** អត្តលេខ ០២២៧៦៤ នាយរងផ្នែកបច្ចេកទេស
យោធភូមិភាគពិសេស

៤៦-វរសេនីយ៍ត្រី **យស់ គឹមអាន** អត្តលេខ ០៣៥៩៩១ អនុមន្ទីរភស្តុភារបច្ចេកទេស
កងរាជអាវុធហត្ថខេត្តព្រះសីហនុ

៤៧-អនុសេនីយ៍ឯក **ទ្រឹក ទ្រី** អត្តលេខ ០២៤២៦៦ នាយរង ក្រុមប្រតិបត្តិការកណ្តាល
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៤៨-អនុសេនីយ៍ឯក **ខ៉ា ចន្ធូ** អត្តលេខ ០១៨៨២៧ នាយរង ក្រុមប្រតិបត្តិការកណ្តាល
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៤៩-អនុសេនីយ៍ឯក **ស៊ុន សុទ្ធីខុឡ្ស** អត្តលេខ ០១៨៧១៨ ជំនួយការមណ្ឌលពិសេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥០-អនុសេនីយ៍ឯក **គុយ ចំរើន** អត្តលេខ ០២៨២១៨ ជំនួយការមណ្ឌលពិសេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥១-អនុសេនីយ៍ឯក **ឌី ចាន់តីរុណា** អត្តលេខ ០១៨៧៩៨ ជំនួយការមណ្ឌលពិសេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥២-អនុសេនីយ៍ឯក **ឡៅ ឡាំសត្ថា** អត្តលេខ ០១០២០៤ ជំនួយការមណ្ឌលពិសេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥៣-អនុសេនីយ៍ឯក **ឃី ឆត** អត្តលេខ ០២៤០៥៥ នាយ ច្រកលក នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥៤-អនុសេនីយ៍ឯក **កៅ ចាន់តារា** អត្តលេខ ០២៤០៥៤ នាយក្រុមប្រតិ.ច្រកត្រពាំងរពៅ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥៥-អនុសេនីយ៍ឯក **ឡាច ខ៉ាន់ដែន** អត្តលេខ ០៣៥១០៦ នាយក្រុមប្រតិ.ច្រកកំពង់ផែអន្តរជាតិ ខេត្តកំពត នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥៦-អនុសេនីយ៍ឯក **ឡើក នាន** អត្តលេខ ០២៤២៣៤ នាយក្រុម ប្រតិ.ក្រុងកែប នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥៧-អនុសេនីយ៍ឯក **ផន់ ទិបុល** អត្តលេខ ១៥៨៧៥៧ នាយរងក្រុមប្រតិបត្តិការ ខេត្តព្រះសីហនុ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥៨-អនុសេនីយ៍ឯក **គោត សម្បត្តិ** អត្តលេខ ០១៨៧៨១ នាយរងក្រុមប្រតិបត្តិការ ខេត្តព្រះសីហនុ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៥៩-អនុសេនីយ៍ឯក **ម៉ម សារិន** អត្តលេខ ០២៤២៣០ នាយក្រុម ប្រតិ.ច្រកថ្មបាំង នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦០-អនុសេនីយ៍ឯក **ណុប ឈួន** អត្តលេខ ០២៤១៩៤ នាយរង ក្រុម ប្រតិ.ខេត្តតាកែវ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦១-អនុសេនីយ៍ឯក **គីម កែវមុន្នីះ** អត្តលេខ ០២៤០៦២ នាយរង ក្រុម ប្រតិ.ខេត្តតាកែវ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦២-អនុសេនីយ៍ឯក **សំ សុគន្ធ** អត្តលេខ ០២៤២៣៨ នាយក្រុម ប្រតិ.ច្រកបាក់ដៃ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦៣-អនុសេនីយ៍ឯក **ឈី មីសារ៉ែន** អត្តលេខ ០២៤០៦៦ នាយក្រុមប្រតិ.ច្រកភ្នំឌិន នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦៤-អនុសេនីយ៍ឯក **ចាន់ រិទ្ធី** អត្តលេខ ០១០២១០ ជំនួយការមណ្ឌល៣ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦៥-អនុសេនីយ៍ឯក **តាន់ ស៊ុនហ៊ួត** អត្តលេខ ០១៨៨៩០ ជំនួយការមណ្ឌល៣ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦៦-អនុសេនីយ៍ឯក **យិន ទីរិយ៉ា** អត្តលេខ ០១៨៨៧៨ ជំនួយការមណ្ឌល៣ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦៧-អនុសេនីយ៍ឯក **លី ម៉េង** អត្តលេខ ០២៤០៥៣ ជំនួយការមណ្ឌល៣ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៦៨-អនុសេនីយ៍ឯក	**សុខ**	**យ៉ានី**	អត្តលេខ ០២៨១៩៩	ជំនួយការមណ្ឌល៣ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៦៩-អនុសេនីយ៍ឯក	**នាង**	**ម៉ាន់ថា**	អត្តលេខ ០២៨០៨៧	ជំនួយការមណ្ឌល៣ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧០-អនុសេនីយ៍ឯក	**ណុច**	**វណ្ណា**	អត្តលេខ ០២៨១៨៨	ជំនួយការមណ្ឌល៣ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧១-អនុសេនីយ៍ឯក	**ស្រ៊ី**	**សាវុធ**	អត្តលេខ ០១៨៧១៩	ជំនួយការ ហិរញ្ញវត្ថុ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧២-អនុសេនីយ៍ឯក	**ទី**	**គឹមអ៊ាង**	អត្តលេខ ០១៨៧១៨	ជំនួយការ យោធបរិក្ខា នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧៣-អនុសេនីយ៍ឯក	**សៅ**	**សុខុម**	អត្តលេខ ០១៨៧៥២	ជំនួយការ ហិរញ្ញវត្ថុ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧៤-អនុសេនីយ៍ឯក	**ហួត**	**ដាទួន**	អត្តលេខ ០១៨៨៦៩	ជំនួយការ សុខាភិបាល នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧៥-អនុសេនីយ៍ឯក	**ទឹម**	**តារី**	អត្តលេខ ០២៨៣០២	ជំនួយការ សុខាភិបាល នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧៦-អនុសេនីយ៍ឯក	**ទៀ**	**លាង**	អត្តលេខ ០២៨០៥២	ជំនួយការ យន្តយុទ្ធ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧៧-អនុសេនីយ៍ឯក	**ឈឹម**	**សារ៉េត**	អត្តលេខ ០១៨៧១២	ជំនួយការ លេខាធិការដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧៨-អនុសេនីយ៍ឯក	**ផុន**	**តា**	អត្តលេខ ០១៨៩៥៨	ជំនួយការ លេខាធិការដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៧៩-អនុសេនីយ៍ឯក	**ខាំ**	**ជុំ**	អត្តលេខ ០២៨១៧៨	ជំនួយការ លេខាធិការដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨០-អនុសេនីយ៍ឯក	**សុភ**	**វណ្ណា**	អត្តលេខ ០២២៩០៦	ជំនួយការ លេខាធិការដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨១-អនុសេនីយ៍ឯក	**អ៊ុង**	**សុខែម**	អត្តលេខ ០២៨២១៨	ជំនួយការ លេខាធិការដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨២-អនុសេនីយ៍ឯក	**សេង**	**បុទុម**	អត្តលេខ ០២៨២១៣	ជំនួយការ លេខាធិការដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨៣-អនុសេនីយ៍ឯក	**អុន**	**សំអឿន**	អត្តលេខ ០១៨៧៩៩	ជំនួយការ ការិយាល័យសន្តិសុខ នាយកដ្ឋានស្រាវជ្រាវចារកិច្ច

៨៤-អនុសេនីយ៍ឯក	**ខែន ចំណាប់**	អត្តលេខ ០១៨៨៥២	ជំនួយការ ការិយាល័យសន្តិសុខ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨៥-អនុសេនីយ៍ឯក	**នីម សារឿន**	អត្តលេខ ០៣៥០៦៦	ជំនួយការ ការិយាល័យសន្តិសុខ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨៦-អនុសេនីយ៍ឯក	**នួច ណារិទ្ធ**	អត្តលេខ ០១៨៩៥៦	ជំនួយការ ការិយាល័យសន្តិសុខ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨៧-អនុសេនីយ៍ឯក	**គឹម រតនៈ**	អត្តលេខ ០២៥២២៨	ជំនួយការ ការិយាល័យសន្តិសុខ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨៨-អនុសេនីយ៍ឯក	**សោម សុតារ៉ូ**	អត្តលេខ ០២៥១៦៥	ជំនួយការ ការិយាល័យសន្តិសុខ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៨៩-អនុសេនីយ៍ឯក	**តែង ខែង**	អត្តលេខ ០២៥១៦៧	ជំនួយការ ការិយាល័យសន្តិសុខ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩០-អនុសេនីយ៍ឯក	**ហ៊ួ សុភន**	អត្តលេខ ០២៥១៣៨	ជំនួយការ ការិយាល័យសន្តិសុខ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩១-អនុសេនីយ៍ឯក	**សំ រិទ្ធស៊ាខលី**	អត្តលេខ ០១៥៧៥៧	ជំនួយការ ការិយាល័យហ្វឹកហ្វឺន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩២-អនុសេនីយ៍ឯក	**សឿង ម៉ាន់**	អត្តលេខ ០២៥១១០	នាយផ្នែកពត៌មានអន្តរជាតិ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩៣-អនុសេនីយ៍ឯក	**ដុំ ចាន់ធ**	រអត្តលេខ ០១០២០០	ជ ការិយាល័យសរុបវិភាគពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩៤-អនុសេនីយ៍ឯក	**រស់ គឹមហេង**	អត្តលេខ ០១៥៩២៨	ជ ការិយាល័យសរុបវិភាគពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩៥-អនុសេនីយ៍ឯក	**ឌី សារ៉ន**	អត្តលេខ ០២៥១៦៩	ជ ការិយាល័យសរុបវិភាគពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩៦-អនុសេនីយ៍ឯក	**ឡាប ញ្ញាខុធ**	អត្តលេខ ០២៥២៩២	ជ ការិយាល័យសរុបវិភាគពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩៧-អនុសេនីយ៍ឯក	**ខ្សៀ ញឹក**	អត្តលេខ ០២៥១០៧	ជ ការិយាល័យសរុបវិភាគពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩៨-អនុសេនីយ៍ឯក	**សេង ប៊ុនហាត់**	អត្តលេខ ០២៥១០៦	ជ ការិយាល័យសរុបវិភាគពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
៩៩-អនុសេនីយ៍ឯក	**ខុធ ធិបុល**	អត្តលេខ ០៥៧៩២១	ជ ការិយាល័យសរុបវិភាគពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១០០-អនុសេនីយ៍ឯក	**ម៉ែន សុទ្ធ**	អត្តលេខ ០២៨១០៨	ជ.ការិយាល័យសរុបវិភាគពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០១-អនុសេនីយ៍ឯក	**តិច សុខថាន**	អត្តលេខ ០២៨១៧០	នាយផ្នែកវិភាគទំនាក់ទំនងពត៌មាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០២-អនុសេនីយ៍ឯក	**ជា សំណាក់**	អត្តលេខ ០២៨១៦០	នាយផ្នែកប្រតិ.ក្រៅប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០៣-អនុសេនីយ៍ឯក	**ឡាយ ពិសី**	អត្តលេខ ០៣៥០៩៩	នាយផ្នែកបច្ចេកទេសចារកិច្ច នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០៤-អនុសេនីយ៍ឯក	**ជា ស៊ីណា**	អត្តលេខ ០១៨៨៦៤	ជំនួយការ ការិ.ប្រតិ.ក្រៅប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០៥-អនុសេនីយ៍ឯក	**ឌុល ឈាង**	អត្តលេខ ០២៣៨២៤	ជំនួយការ ការិ.ប្រតិ.ក្រៅប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០៦-អនុសេនីយ៍ឯក	**ព្រំ ស៊ុំ**	អត្តលេខ ០៣៥១០២	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០៧-អនុសេនីយ៍ឯក	**ស្វាយ សារ៉ុន**	អត្តលេខ ០១៨៨៤០	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០៨-អនុសេនីយ៍ឯក	**ម៉េង តារា**	អត្តលេខ ០១០២៣១	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១០៩-អនុសេនីយ៍ឯក	**សុខ មុន្នី**	អត្តលេខ ០១៨៨៥៩	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១១០-អនុសេនីយ៍ឯក	**ឌី សារ៉ាវុធ**	អត្តលេខ ០១៨៧៥៣	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១១១-អនុសេនីយ៍ឯក	**ម៉េង វណ្ណា**	អត្តលេខ ០១៨៨៤៥	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១១២-អនុសេនីយ៍ឯក	**ពៅ ពិសិដ្ឋ**	អត្តលេខ ០១៨៨៨១	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១១៣-អនុសេនីយ៍ឯក	**ហេង ចាន់មន្នី**	អត្តលេខ ០១៨៨៥៨	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១១៤-អនុសេនីយ៍ឯក	**ផាន់ ផាន្នី**	អត្តលេខ ០២៨១៧៦	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១១៥-អនុសេនីយ៍ឯក	**អ៊ុន ឌីម៉ង់**	អត្តលេខ ០២៨២៦៧	ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១១៦-អនុសេនីយ៍ឯក **ឡេង ទិសាល** អត្តលេខ ០២៤២៨៤ ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១១៧-អនុសេនីយ៍ឯក **សូ ឡូប៊ែរ** អត្តលេខ ០២៤១៧៩ ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១១៨-អនុសេនីយ៍ឯក **ម៉ែន ឃុនវិចិត្រ** អត្តលេខ ០២៤០៥០ ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១១៩-អនុសេនីយ៍ឯក **អ៊ឹម ស៊ីឡឿន** អត្តលេខ ០២៤០៧៣ ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២០-អនុសេនីយ៍ឯក **ឡាង ពិសិដ្ឋ** អត្តលេខ ០៤៧៩០៦ ជំនួយការ ការិ.ប្រតិ.ក្នុងប្រទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២១-អនុសេនីយ៍ឯក **ម៉ៅ សារ៉ាក់** អត្តលេខ ០២៤១៣៤ នាយផ្នែក វិទ្យុឯកសារ
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២២-អនុសេនីយ៍ឯក **ពេជ្រ កេត** អត្តលេខ ០១៩៥៦១ ជំនួយការ ការិយាល័យវិទ្យុឯកទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២៣-អនុសេនីយ៍ឯក **ម៉ិល ធឿន** អត្តលេខ ០២៤២៧១ ជំនួយការ ការិយាល័យវិទ្យុឯកទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២៤-អនុសេនីយ៍ឯក **កែវ ម៉ាឡា** អត្តលេខ ០២៤១១៧ ជំនួយការ ការិយាល័យវិទ្យុឯកទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២៥-អនុសេនីយ៍ឯក **ឡាយ សារឿន** អត្តលេខ ០១៨៨២១ ជំនួយការ ការិយាល័យវិទ្យុឯកទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២៦-អនុសេនីយ៍ឯក **ហ៊ីន សុវណ្ណារី** អត្តលេខ ០២៤២១១ ជំនួយការ ការិយាល័យវិទ្យុឯកទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២៧-អនុសេនីយ៍ឯក **ព្រហ្ម ពៅ** អត្តលេខ ០៣៥០៧៧ ជំនួយការ ការិយាល័យវិទ្យុឯកទេស
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២៨-អនុសេនីយ៍ឯក **ម៉ៅ សាវី** អត្តលេខ ០១៨៨២៤ ជំនួយការ ការិយាល័យបុគ្គលិក
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១២៩-អនុសេនីយ៍ឯក **សើរ សារិទ្ធ** អត្តលេខ ០១៨៨៥៣ ជំនួយការ ការិយាល័យបុគ្គលិក
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣០-អនុសេនីយ៍ឯក **ទ្រី ចំរើន** អត្តលេខ ០១៨៨៧៧ ជំនួយការ ការិយាល័យបុគ្គលិក
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣១-អនុសេនីយ៍ឯក **ឡៀង ណារិទ្ធ** អត្តលេខ ០២៤០៥២ ជំនួយការ ការិយាល័យបុគ្គលិក
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣២-អនុសេនីយ៍ឯក **សែ បុណ្យអេង** អត្តលេខ ០១៦៩៩០ ជំនួយការ ការិយាល័យបុគ្គលិក
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣៣-អនុសេនីយ៍ឯក **មិន ពៅ** អត្តលេខ ០២៨១៨៥ ជំនួយការ ការិយាល័យបុគ្គលិក
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣៤-អនុសេនីយ៍ឯក **ស្រ៊ុន ប៊ុណ្ណារ៉ូ** អត្តលេខ ០២៨០៨៣ នាយរង ក្រុម ប្រតិ.ខេត្តសៀមរាប
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣៥-អនុសេនីយ៍ឯក **ស៊ី ម៉ៅ** អត្តលេខ ២២៦៨៧៨ នាយរងក្រុម ប្រតិ. ខេត្តឧត្តរមានជ័យ
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣៦-អនុសេនីយ៍ឯក **ត្រី សុវណ្ណាដេត** អត្តលេខ ០២៨០៩២ នាយក្រុមប្រតិ.ច្រកជាំក្សាន្ត
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣៧-អនុសេនីយ៍ឯក **ហោច ជំនិត** អត្តលេខ ០៣៥០៦៣ នាយក្រុមប្រតិ.ច្រកជុបគគីរ
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣៨-អនុសេនីយ៍ឯក **ឡុង រិទ្ធី** អត្តលេខ ០៣៥០៩៣ នាយក្រុមប្រតិ.ច្រកថ្មដូន
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៣៩-អនុសេនីយ៍ឯក **ហ៊ុន សុខសាន** អត្តលេខ ០២៨២៥៥ នាយក្រុមប្រតិ.ច្រកជប់រុន
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤០-អនុសេនីយ៍ឯក **អ៊ិន សុតី** អត្តលេខ ០២៨០៥១ ជំនួយការ ក្រុមប្រតិ.ខេត្តកំពង់ធំ
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤១-អនុសេនីយ៍ឯក **ម៉ែន ម៉ុនតា** អត្តលេខ ០២៥៨៣៥ ជំនួយការ ក្រុមប្រតិ.ខេត្តកំពង់ធំ
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤២-អនុសេនីយ៍ឯក **សំ សុខែម** អត្តលេខ ០២៦៨៨៩ ជ.ក្រុមប្រតិបត្តិការខេត្តព្រះវិហារ
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤៣-អនុសេនីយ៍ឯក **ឈួន គឹមហ៊ី** អត្តលេខ ០១០២២៣ ជំនួយការ មណ្ឌល ៤
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤៤-អនុសេនីយ៍ឯក **ស៊ុំ សុខណារ្ត្រី** អត្តលេខ ០៤៩៦៦១ ជំនួយការ មណ្ឌល ៤
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤៥-អនុសេនីយ៍ឯក **ឃុត គឹមលាន** អត្តលេខ ០១៨៩២០ ជំនួយការ មណ្ឌល ៤
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤៦-អនុសេនីយ៍ឯក **ពុទ្ធ សុទ្ធិរិទ្ធ** អត្តលេខ ០១៨៩៨៥ ជំនួយការ មណ្ឌល ៤
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤៧-អនុសេនីយ៍ឯក **ចាន់ គង់** អត្តលេខ ០២៨២៩៦ ជំនួយការ មណ្ឌល ៤
នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៤៨-អនុសេនីយ៍ឯក	**ជួន ចិន**	អត្តលេខ ០៣៥០៩២	ជ ក្រុមប្រតិ.ខេត្តឧត្តរមានជ័យ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៤៩-អនុសេនីយ៍ឯក	**មិត ថៃល**	អត្តលេខ ០៣៥០៦៥	ជ ក្រុមប្រតិ.ខេត្តឧត្តរមានជ័យ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥០-អនុសេនីយ៍ឯក	**តួច រ័ត្ន**	អត្តលេខ ០២៨១៥០	ជំនួយការ មណ្ឌល ៨ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥១-អនុសេនីយ៍ឯក	**ខៀវ ចិន្តា**	អត្តលេខ ០១៨៧២៥	ជំនួយការ នាយកដ្ឋាន នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥២-អនុសេនីយ៍ឯក	**ញ៉ាញ់ ស៊ិនឌី**	អត្តលេខ ០១០២៨៤	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥៣-អនុសេនីយ៍ឯក	**ហៀក ស៊ីវប៉ាវ**	អត្តលេខ ០១៨៧៣៣	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥៤-អនុសេនីយ៍ឯក	**ខៀប ដាវិន**	អត្តលេខ ០១៨៧១៦	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥៥-អនុសេនីយ៍ឯក	**គឹម ចាន់តារា**	អត្តលេខ ០២៨១៦៦	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥៦-អនុសេនីយ៍ឯក	**លី ម៉េងហឺ**	អត្តលេខ ០៣៥០៩៦	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥៧-អនុសេនីយ៍ឯក	**ឡាំ ម៉ុនលាង**	អត្តលេខ ០២៨១១៨	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥៨-អនុសេនីយ៍ឯក	**ប៊ុន ធុទ្ធី**	អត្តលេខ ០២៨០៩៣	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៥៩-អនុសេនីយ៍ឯក	**ដេត ណាវុធ**	អត្តលេខ ០៣៥០៩៧	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦០-អនុសេនីយ៍ឯក	**ខេ ដួចដាក៉ាទិចឡ្សន៍**	អត្តលេខ ០២០៩៧៥	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦១-អនុសេនីយ៍ឯក	**ម៉េង ប៊ុនណារិន**	អត្តលេខ ០២៨០៩៧	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦២-អនុសេនីយ៍ឯក	**សឿន ស៊ាន**	អត្តលេខ ០២៨០៨២	ជំនួយការ ការិយាល័យបុគ្គលិក នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦៣-អនុសេនីយ៍ឯក	**លី វណ្ណារិទ្ធ**	អត្តលេខ ០២៨២១៦	នាយរង ក្រុមប្រតិ.ខេត្តរតនគីរី នាយកដ្ឋានស្រាវជ្រាវចារកិច្ច

១៦៤-អនុសេនីយ៍ឯក	**យស សិទ្ធ**	អត្តលេខ ០២៤២២៦	នាយក្រុម ប្រតិ. ច្រកអូរយាដាវ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦៥-អនុសេនីយ៍ឯក	**ថោង ពុទ្ធី**	អត្តលេខ ០២០៧១៦	នាយច្រកព្រលានយន្តហោះរតនៈគីរី នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦៦-អនុសេនីយ៍ឯក	**ខៀវ ខ៉ា**	អត្តលេខ ០២៤២៣២	ជំនួយការ មណ្ឌល ១ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦៧-អនុសេនីយ៍ឯក	**ខន ចាន់ណាខុធ**	អត្តលេខ ០១៤៧២៩	ជំនួយការ មណ្ឌល ១ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
១៦៨-អនុសេនីយ៍ឯក	**អ៊ិត លន់**	អត្តលេខ ០១៤៩០៨	ជំនួយការមណ្ឌល២ នាយកដ្ឋានស្រាវជ្រាវចារកិច្ច
